សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការអនុវត្តអាហារកាតព្វកិច្ច ៖ បញ្ហាប្រឈម និងផលវិបាក

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ ៖

និស្សិតឈ្មោះ ៖ **ជួន លីហេង**

**ក.ម៉ាអេល ម៉ាលីន**

សាស្ត្រាចារ្យណែនាំ

លោក **ហាប់ ផល្លី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**


# សារណាបញ្ចប់ការសិក្សា

# ការអនុវត្តអាហារកាតព្វកិច្ច ៖ បញ្ហាប្រឈម និងផលវិបាក

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ ៖ | សាស្ត្រាចារ្យណែនាំ

និស្សិតឈ្មោះ ៖ **ជួន លីហេង** | លោក **ហាប់ ផល្លី**

**ក.ម៉ាអេល ម៉ាលីន**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ** | ឆ្នាំចូលសិក្សា ២០១៦

ជំនាន់ទី២០ | ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ម៉ាអេល ម៉ាលីន** ជានិស្សិតថ្នាក់ L4C1 និង **ជួន លីហេង** ជានិស្សិតថ្នាក់ L4C3 នៃថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៩-២០២០។

## សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

**លោកឪពុក** និង **អ្នកម្តាយ** ដែលបានខិតខំបីបាច់ថែរក្សារូបកូនតាំងពីតូចក្រូចឆ្មាររហូតដល់ធំពេញវ័យ ដោយក្តីស្រលាញ់ និងពោរពេញដោយសេចក្តីសណ្តោសប្រណី និងជាទឹកចិត្តដ៏ថ្លៃថ្លាដែលមានតម្លៃមហាសាលពុំអាចកាត់ថ្លៃបាន។

លោកឪពុកអ្នកម្តាយ ជាអ្នកមានគុណដ៏ឧត្តុង្គឧត្តមបំផុតសម្រាប់កូនៗ ដោយលោកបានផ្តល់កំណើតដល់រូបយើងខ្ញុំ ហើយបានលះបង់ទាំងកម្លាំងកាយចិត្ត ញើសឈាម ក្នុងការចិញ្ចឹមបីបាច់ថែរក្សាទំនុកបម្រុងដល់កូនៗ ទាំងផ្នែកស្មារតី និងផ្គត់ផ្គង់ទាំងសម្ភារៈក្នុងការរស់នៅរបស់កូន។ លើសពីនេះទៅទៀត លោកទាំងពីរបានអប់រំ ទូន្មានប្រៀនប្រដៅកូនៗប្រកបដោយព្រហ្មវិហារធម៌គឺមេត្តា ករុណា មុទិតា និងឧបេក្ខា ជាមួយនឹងគុណធម៌ដ៏វិសេសវិសាល ថ្លៃថ្លាលើសមាសពេជ្រ មិនអាចកាត់ថ្លៃបានសម្រាប់កូន។ លោកទាំងពីរ ខិតខំតស៊ូ អត់ធ្មត់ក្នុងភាពលំបាក ឱ្យតែកូនបានរៀនសូត្រ លះបង់ទាំងកម្លាំងកាយចិត្ត ទ្រព្យធន់ លុយកាក់ ដែលខិតខំរកមកដោយញើសឈាមស្រស់ៗក្រោមកម្តៅព្រះអាទិត្យសែនក្តៅ។ រយៈពេល១៦ឆ្នាំមកនេះ ដែលលោកស៊ូរលំបាកដើម្បីឱ្យកូនបានរៀនសូត្រខ្ពង់ខ្ពស់ តាំងពីថ្នាក់បឋមសិក្សាមក រហូតបញ្ចប់ថ្នាក់ឧត្តមសិក្សា ប្រកបដោយភាពជោគជ័យយ៉ាងត្រចះត្រចង់ដូចថ្ងៃនេះ ក៏ដូចជាដើម្បីជាការជម្រុញឲ្យយើងខ្ញុំក្លាយជាបញ្ញវ័ន្តដែលមានវិជ្ជាជីវៈ មានចំណេះជំនាញពិតប្រាកដ ប្រកបដោយក្រមសិលធម៌ គុណធម៌ សច្ចៈធម៌ នៅក្នុងសង្គម។ យើងខ្ញុំជាកូនៗ សូមក្រាបលំឱនកាយគោរពនូវមហាករុណាទិគុណ ដ៏មហិមារនេះ ស្ថិតក្នុងការចងចាំកូនៗតរៀងទៅ។

ជាកិច្ចបន្ទាប់យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបង្ហាត់បង្រៀនយើងខ្ញុំ តាំងពីថ្នាក់បឋមសិក្សា រហូតបញ្ចប់មហាវិទ្យាល័យប្រកបដោយភាពជោគជ័យ។ ជាពិសេសយើងខ្ញុំ ក៏សូថ្លែងអំណរគុណផងដែរចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំទាំងកម្លាំងកាយចិត្ត រិះរកគ្រប់វិធីសាស្ត្រ ក្នុងការបង្ហាត់បង្រៀនផ្ទេរចំណេះដឹងដល់រូបយើងខ្ញុំ រហូតចប់បរិញ្ញាបត្រនីតិសាស្ត្រនេះ។ លើសពីនេះទៅទៀត យើងខ្ញុំក៏គោរព និងដឹងគុណយ៉ាងជ្រាលជ្រៅផងដែរចំពោះលោកសាស្ត្រាចារ្យ **ហាប់ ផល្លី** ដែលបានណែនាំសារណាបញ្ចប់ការសិក្សាលើប្រធានបទមួយនេះ។ លោកបានផ្តល់នូវដំបូន្មានល្អៗ ក៏ដូចជាគន្លឹះក្នុងការសិក្សាស្រាវជ្រាវ វិធីសាស្ត្រក្នុងការ

ចងក្រងសារណា និងការកែលម្អឲ្យកាន់តែល្អប្រសើរជាងមុនថែមទៀត។ ជាមួយគ្នានេះផងដែរ យើងខ្ញុំក៏សូមអគុណចំពោះលោក លោកស្រីបណ្ណារក្ស រាមច្បង និងមិត្តនិស្សិតទាំងអស់ដែលបានជួយផ្តល់ជាមតិយោបល់ការណែនាំផ្សេងៗ ក៏ដូចជាការជួយផ្តល់នូវឯកសារដែលពាក់ព័ន្ធនឹងប្រធានបទមួយនេះ សម្រាប់ធ្វើដើមជាទុនក្នុងការសសេរសារណានេះ ដើម្បីបន្សល់ទុកជាឯកសារបន្តដល់មិត្តនិស្សិតជំនាន់ក្រោយៗទៀត។

ជាទីបញ្ចប់យើងខ្ញុំសូមធ្វើការសុំអធ្យាស្រ័យ មេត្តាខន្តីអភ័យទោសនូវរាល់ចំណុចអវិជ្ជមាន ដែលតែងកើតមានដោយចៀសមិនផុត រួមមាន ការប្រើប្រាស់ពាក្យពេចន៍ អក្ខរាវិរុទ្ធដែលកើតមានឡើងដោយអចេតនាស្របពេលជាមួយគ្នានេះយើងខ្ញុំលើកដៃប្រណមបួងសួង ដល់គ្រប់វត្ថុសក្តិសិទ្ធទាំងអស់នៅក្នុងពិភពសន្និវាសនេះ រួមទាំងអារក្សទេវតាអ្នករក្សាភពតាំងប្រាំបីទិស ប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខគ្រប់ប្រការ សូមកើតមានចំពោះអ្នកមានគុណទាំងពីរ ព្រមទាំងលោក **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរងព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ** ទាំងអស់ប្រកបដោយសេចក្តីសុខ និងសម្រេចនូវរាល់បំណងប្រាថ្នាទាំងពួង។

# អារម្ភកថា

សារណាបញ្ចប់ការសិក្សា គឺជាគោលបំណងយើងខ្ញុំតាំងតែពីថ្ងៃដំបូងនៃការឈានជើងចូលរៀននៅថ្នាក់មហាវិទ្យាល័យមកម្ល៉េះ ។ មកទល់នឹងពេលនេះ ឪកាសនេះបានមកដល់ហើយ ដែលជាមូលហេតុតម្រូវឲ្យយើងខ្ញុំសម្រេចចិត្តធ្វើការជ្រើសរើសយកមប្រធានបទសារណាអំពី **ការអនុវត្តអាហារកាតព្វកិច្ច ៖ បញ្ហាប្រឈម និងផលវិបាក**។ ប្រធានបទមួយនេះគឺជាកម្មវត្ថុចម្បង គឺដើម្បីលើកកម្ពស់គុណភាពនៃការរស់នៅក្នុងសង្គមកម្ពុជាយើងនេះ។ យ៉ាងណាមិញដែលកាន់តែសំខាន់ទៅទៀត ក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទមួយនេះ គឺដើម្បីបើកបង្ហាញអំពីចន្លោះខ្វះខាត ក៏ដូចជាបញ្ហាប្រឈមមួយចំនួនដែលតែងតែកើតឡើងនៅកំឡុងពេលអនុវត្តនូវរបបអាហារកាតព្វកិច្ច ក៏ដូចជាការចង្អុលបង្ហាញពីគុណវិបាកដែលកើតឡើងជាបន្តបន្ទាប់ផងដែរ។

យើងខ្ញុំសង្ឃឹមក្នុងចិត្តយ៉ាងមុតមាំថា ការស្រាវជ្រាវមួយនេះ ពិតជាមានសារៈប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវសម្រាប់អ្នកសិក្សាជំនាន់ក្រោយៗ ក៏ដូចជាមិត្តអ្នកអាន អ្នកស្រាវជ្រាវដទៃទៀតមិនខាន។ ការសិក្សាស្រាវជ្រាវនេះ ជាសមិទ្ធផលដែលកើតឡើងពីការខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់យើងខ្ញុំ ដោយពឹងផ្អែកលើចំណេះដឹងផ្ទាល់ខ្លួន ក៏ដូចជាការប្រើប្រាស់នូវឯកសារមូលដ្ឋានផ្សេងៗជាច្រើនទៀត ដើម្បីជាគ្រឹះក្នុងការស្រាយចម្ងល់ដែលមានក្នុងប្រធានបទមួយនេះ ក៏ដូចជាការបំភ្លឺដល់ខ្លួនឯង រួមទាំងមិត្តនិស្សិត និងមិត្តអ្នកសិក្សាស្រាវជ្រាវដទៃទៀត ជាពិសេសប្រជាពលរដ្ឋខ្មែរទាំងអស់ដែលមានបំណងចង់យល់ច្បាស់អំពីបញ្ហាពាក់ព័ន្ធនឹងការផ្គត់ផ្គង់ និងការទាមទារអាហារកាតព្វកិច្ច រួមទាំងបញ្ហាប្រឈមផ្សេងៗដែលអាចនឹងកើតឡើង កំឡុងពេល និងក្រោយពេលអនុវត្តនូវរបបអាហារកាតព្វកិច្ចនេះ។

តែទោះជាយ៉ាងនេះក្តី ក្នុងនាមយើងខ្ញុំទាំងពីរ ជាអ្នកសិក្សាស្រាវជ្រាវ និងចងក្រងឯកសារនេះរមែងតែចៀសមិនផុតពីកំហុសឆ្គងដោយអចេតនា រួមមាន ការប្រើប្រាស់ពាក្យពេចន៍ អក្ខរាវិរុទ្ធ ខ្លឹមសារ ឬអត្ថន័យនៅក្នុងអត្ថបទក្តី ដែលកើតមានឡើង។ អាស្រ័យហេតុនេះ យើងខ្ញុំសូមធ្វើការសុំក្តីមេត្តាអធ្យាស្រ័យ និងជួយកែតម្រូវ ដើម្បីកិច្ចការស្រាវជ្រាវមួយនេះកាន់តែមានភាពល្អប្រសើរជាងមុន។ យើងខ្ញុំរង់ចាំទទួលរាល់មតិរិះគន់ និងស្ថាបនា ក្នុងបំណងកែលម្អអត្ថបទនេះកាន់តែល្អ ស៊ីជម្រៅ និងសុក្រឹត្យជាងមុន

**មាតិកា** **ទំព័រ**

## សេចក្តីផ្តើម

**១. លំនាំបញ្ហានៃការស្រាវជ្រាវ** ........ ១

**២. ចំណោទបញ្ហានៃការស្រាវជ្រាវ** ........ ២

**៣. គោលបំណងនៃការស្រាវជ្រាវ** ........ ២

**៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ** ........ ២

**៥. វិធីសាស្ត្រនៃការស្រាវជ្រាវ** ........ ៣

**៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ........ ៣

## ជំពូកទី១

## សញ្ញាណនៃរបបអាហារកាតព្វកិច្ច

**១.១. និយមន័យ** ........ ៤

**១.២. ការវិវត្តន៍នៃរបបអាហារកាតព្វកិច្ច** ........ ៤

១.២.១. អាហារកាតព្វកិច្ចច្បាប់ចាស់ ........ ៤

១.២.២. អាហារកាតព្វកិច្ចសម័យបច្ចុប្បន្ន ........ ៥

## ជំពូកទី២

## ការកំណត់ពីរបបអាហាកាតព្វកិច្ច

**២.១. តួអង្គក្នុងការអនុវត្ត** ........ ៧

២.១.១. ញាតិភាព ........ ៧

២.១.១.១. បុគ្គលដែលមានសិទ្ធិក្នុងការទាមទារអាហារកាតព្វកិច្ច ........ ៨

២.១.១.២. បុគ្គលដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ........ ៨

២.១.១.៣. ទំនាក់ទំនងនៃញាតិភាព ........ ៩

ក. ញាតិដែលរស់នៅជាមួយគ្នា ........ ៩

២.១.២. ញាតិលោហិតខ្សែផ្ទាល់ ........ ១១
២.១.៣. បងប្អូនបង្កើត ........ ១១
២.១.៤. ញាតិដែលកំណត់ដោយសេចក្តីសម្រេចរបស់តុលាការ ........ ១២
២.១.៤.១. ញាតិក្នុងថ្នាក់ទី៣ ........ ១២
ក. ករណីគ្មានញាតិដែលកំណត់ដោយច្បាប់ ........ ១២
២.១.៤.២. ញាតិពន្ធក្រោយមរណៈភាពនៃសហព័ទ្ធណាម្ខាង ........ ១៣
២.១.៥. សហព័ទ្ធ ........ ១៣
២.១.៦. កូនជាអនីតិជន ........ ១៤
**២.២. មធ្យោបាយក្នុងការសម្រេចពីការអនុវត្ត** ........ ១៥
២.២.១.១. ការចរចា ........ ១៥
២.២.១.២. សន្ធានកម្ម ........ ១៦
២.២.២. ការទាមទារសិទ្ធិក្នុងការទទួលបានអាហារកាតព្វកិច្ច ........ ១៧
២.២.២.១. បរាជ័យក្នុងការពិភាក្សា ........ ១៧
២.២.២.២. ការមិនព្រមទទួលសំណើ ........ ១៧

## ជំពូកទី៣
## វត្តមាននៃអាហារកាតព្វកិច្ច

**៣.១. សារប្រយោជន៍ និង ផលអវិជ្ជមាន** ........ ១៩
៣.១.១. ផលវិជ្ជមាននៃអាហារកាតព្វកិច្ច ........ ១៩
៣.១.១.២ សមភាពក្នុងការរស់នៅ ........ ១៩
**៣.២. ផលអវិជ្ជមាន** ........ ២០
៣.២.១. ការកើនឡើងនូវបន្ទុក ........ ២០

**៣.២. ការជួបប្រទះបញ្ហាក្នុងការអនុវត្ត**....................................................................... ២១
៣.២.១. ការបង់ផ្តាច់ ........................................................................................... ២១
៣.២.១.១. ការបង់ផ្តាច់ក្នុងចំណងញាតិ ................................................................... ២១
៣.២.១.២ ការបង់ផ្តាច់ចំពោះអតីតសហព័ទ្ធ ......................................................... ២២
៣.២.១.៣ កូនជាអនីតិជន ..................................................................................... ២៤
៣.២.២ អនុភាពនៃការមិនអនុវត្តអាហារកាតព្វកិច្ច .................................................. ២៦
៣.២.២.១.អនុភាពចំពោះជនដែលជាប់ករណីយកិច្ច ........................................................ ២៦
**សេចក្តីសន្និដ្ឋាន** ........................................................................................... ៣០
**អនុសាសន៍** ................................................................................................... ៣១
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន បញ្ហាទាក់ទងនឹងអាហារកាតព្វកិច្ចដែលមានកំណត់តាំងពីច្បាប់ចាស់មកនោះ គឺស្ថិតនៅក្នុងភាពមិនច្បាស់លាស់នៅក្នុងផ្នត់គំនិតរបស់ប្រជាជនកម្ពុជានៅឡើយទេ។ ប្រជាជនកម្ពុជាខ្លះមិនទាន់បានយល់ផងថា អ្វីទៅជាអាហារកាតព្វកិច្ច ដោយនៅតែគិតថា អាហារកាតព្វកិច្ចគឺជាពាក្យថ្មីដែលមិនធ្លាប់បានដឹងពីមុនមក កត្តាមួយចំនួននេះហើយសុទ្ធសឹងតែជាបញ្ហាដែលតម្រូវឲ្យមានការបកស្រាយពន្យល់បន្ថែម ព្រមទាំងបង្ហាញទៅកាន់សាធារណៈជនឲ្យបានយល់ច្បាស់។ ក្នុងរូបភាពជាអាហារកាតព្វកិច្ចដែលប្រជាជនកម្ពុជាច្រើនបានអនុវត្ត គឺដូចជាការជួយមើលថែរក្សាបុគ្គលដែលមានទំនាក់ទំនងញាតិភាពនឹងគ្នាក្នុងការប្រាស្រ័យទាក់ទងសកម្មភាពប្រចាំថ្ងៃ។ ការទំនុកបម្រុង អប់រំកូនៗដែលនៅក្នុងបន្ទុក ចិញ្ចឹមបីបាច់ប្រៀបប្រដៅកូន ការជួយគ្នាក្នុងគ្រាមានអាសន្នរបស់ញាតិ ក៏ដូចជាការមើលថែផ្គត់ផ្គង់គ្នារបស់សហព័ទ្ធ ជាដើម។ សកម្មភាពដែលប្រជាជនកម្ពុជាបានអនុវត្តសព្វថ្ងៃនេះហើយគឺជាអត្ថន័យនៃអាហារកាតព្វកិច្ច ប៉ុន្តែពួកគាត់មិនមានការចាប់អារម្មណ៍ពីអ្វីដែលខ្លួនឯងបានធ្វើនេះជាអាហារកាតព្វកិច្ចដែលបានកំណត់នៅក្នុងច្បាប់។ ការអនុវត្តតាមទំនៀមទំលាប់ មិនបានស្តែងឡើងតាមការកំណត់ដោយច្បាប់ទេ ដោយគ្រាន់តែមានភាពប្រហាក់ប្រហែលប៉ុណ្ណោះ ព្រោះក្នុងការកំណត់របស់ច្បាប់គឺមានកំណត់ពីបុគ្គលច្បាស់លាស់ដើម្បីអនុវត្តទៅបានដោយប្រសិទ្ធភាព។

អាហារកាតព្វកិច្ចមានប្រភេទដូចជា អាហារកាតព្វកិច្ចផ្គត់ផ្គង់ដោយរដ្ឋ អាហាការព្វកិច្ចដែលកើតចេញពីសេចក្តីសម្រេចរបស់តុលាការក្នុងករណីលែងលះ និងអាហារកាតព្វកិច្ចឯកជនដែលកំណត់ដោយច្បាប់។[1] អាហារកាតព្វកិច្ចសំដៅដល់ការទទួលខុសត្រូវនៃទំនាក់ទំនងញាតិ ប្រសិនបើបុគ្គលម្នាក់ ឬច្រើននាក់ មិនអាចចិញ្ចឹមជីវិតដោយខ្លួនឯងបានទេ មានន័យថាបុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងញាតិនឹងគ្នានោះ ត្រូវធ្វើការទទួលខុសត្រូវ ប្រសិនបើមានការស្នើសុំពីបុគ្គលដែលមានការខ្វះខាតនោះ។ ផ្អែកតាមសេចក្តីនេះ បានសបញ្ជាក់ថា រដ្ឋបានផ្ទេរនូវការទទួលខុសត្រូវមួយចំនួនទៅឲ្យបុគ្គលដែលជាញាតិនឹងគ្នាទៅវិញ នេះគឺជាការចាប់ផ្តើមឲ្យមានឡើងនូវប្រព័ន្ធអាហារកាតព្វកិច្ច។[2]

---

[1] Fresh News, យល់ដឹងផ្នែកច្បាប់៖ អាហារកាតព្វកិច្ចតាមផ្លូវច្បាប់ (ភ្នំពេញ៖ ២០២០), http://m.freshnewsasia.com/index.php/en/localnews/162314-2020-06-14-06-42-02.html (ថតចម្លងថ្ងៃទី ១៤ មេសា ២០២០)។

[2] ស្ថានីយទូរទស្សន៍ BTV, កម្មវិធីនាទីច្បាប់៖ អាហារកាតព្វកិច្ច ( ភ្នំពេញ៖ ឆ្នាំ២០១៦), https://youtu.be/kS__yLCPW5s (ថតចម្លងថ្ងៃទី ១៤ មេសា ២០២០)។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ការធានាឲ្យបាននូវការអនុវត្តរបបអាហារកាតព្វកិច្ចឲ្យមានភាពប្រសិទ្ធភាពគឺជារឿងប្រសើរណាស់ ក្នុងការជួយដល់ការដោះនូវបន្ទុករបស់រដ្ឋដែលបានចំណាយច្រើនក្នុងការផ្គង់ផ្គង់ដល់ប្រជាពលរដ្ឋ ដែលមានភាពខ្វះខាត និងធ្វើការផ្ទេរនូវការទទួលខុសត្រូវមួយចំនួនដល់បុគ្គលដែលមានទំនាក់ទំនងញាតិនឹងគ្នា ដើម្បីបង្ហាញពីទំនាក់ទំនងល្អក្នុងការសង្គម។ ហេតុនេះ ដើម្បីធានាបាននូវការអនុវត្តឲ្យមានប្រសិទ្ធភាពក្នុងដំណើរការប្រព្រឹត្តទៅនៃរបបអាហារកាតព្វកិច្ចនៃបទដ្ឋានគតិយុត្តកម្ពុជា តើអ្វីជាអាហារកាតព្វកិច្ច? តើអាហារកាតព្វកិច្ចត្រូវបានវិវត្តន៍បែបណាខ្លះចាប់តាំងពីក្រមរដ្ឋប្បវេណីចាស់រហូតដល់បច្ចុប្បន្ន? តើជនណាខ្លះ មានកាតព្វកិច្ចក្នុងការផ្គត់ផ្គង់អាហារកាតព្វកិច្ច និងជនណាខ្លះសិទ្ធិក្នុងការទទួលបានអាហារការព្វកិច្ច? តើអាហារកាតព្វកិច្ចបានផ្តល់នូវផលវិជ្ជមាន និង ផលអវិជ្ជមានបែបណាខ្លះ? ហើយស្របគ្នានឹងពេលអនុវត្តផងដែរ តើត្រូវបានជួបប្រទះបញ្ហាប្រឈមយ៉ាងណាខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ប្រធានបទក្នុងការសិក្សាស្រាវជ្រាវមួយនេះ មានគោលបំណងដើម្បីរួមចំណែកដល់ការយល់ដឹងផ្នែកទំនាក់ទំនងឯកជនឲ្យកាន់តែស៊ីជម្រៅទៅលើកាតព្វកិច្ចរបស់បុគ្គលគ្រប់រូបចំពោះញាតិរបស់ខ្លួន ក្នុងការប្រើប្រាស់សិទ្ធិដែលច្បាប់បានផ្តល់ឲ្យ ដើម្បីការប្រាស្រ័យទាក់ទងក្នុងសង្គម សិទ្ធិ និង ករណីយកិច្ចដែលខ្លួនមានចំពោះគ្នា ក៏ដូចជាការយល់ដឹងកាន់តែច្បាស់នោះគឺ របបនៃអាហារកាតព្វកិច្ចដែលមានចែងក្នុងច្បាប់តាំងពីក្រមរដ្ឋប្បវេណីឆ្នាំ១៩២០ មកម្ល៉េះ។ ការស្រាវជ្រាវនេះនឹងបានរួមចំណែកជាទស្សនទានក្នុងការប្រើប្រាស់សិទ្ធិអំណាចឲ្យចំគោលដៅ និងបង្កើននូវចំណេះដឹងឲ្យកាន់តែច្បាស់ទាក់ទងនឹងរបបគត្តិយុត្តនៃអាហារកាតព្វកិច្ច ហើយកាលដែលមានការយល់ដឹងបានស៊ីជម្រៅទៅលើសិទ្ធិ និង ករណីយកិច្ចរបស់ខ្លួនម្នាក់ៗនោះ វានឹងបង្កើតនូវទំនុកចិត្តក្នុងការអនុវត្ត និងប្រើប្រាស់សិទ្ធិរបស់ខ្លួនឯងឲ្យមានប្រសិទ្ធភាពទៀតផង។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

វិសាលភាពនៃកិច្ចការស្រាវជ្រាវនេះ គឺកម្រិតត្រឹមតែអាហារកាតព្វកិច្ចដែលប្រើប្រាស់ក្នុងវិស័យឯកជនប៉ុណ្ណោះ ដែលកើតឡើងដោយទំនាក់ទំនងសហព័ទ្ធ អំណាចមេបាចំពោះកូន និងទំនាក់ទំនងក្នុងទំហំញាតិ។ ការកំណត់បែបនេះក៏ព្រោះតែ អាហារកាតព្វកិច្ច ក៏មានអាហារកាតព្វកិច្ចសាធារណៈដែលត្រូវបានផ្តល់ដោយរដ្ឋ និងសកម្មភាពប្រហាក់ប្រហែលនេះដូចជា សកម្មភាពសប្បុរសធម៌របស់មហាជន អំពើមនុស្សធម៌របស់កាកបាទក្រហម និងសកម្មភាពមនុស្សធម៌ក្រោមរូបភាពផ្សេងៗជាច្រើនទម្រង់ទៀត។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ប្រធានបទសារណានេះ ត្រូវបានសិក្សាស្រាវជ្រាវក្រោមទម្រង់ឯកសារ និងប្រភពព័ត៌មានផ្សេងទៀតដែលបានផ្សាភ្ជាប់ និងបង្កប់អត្ថន័យខ្លឹមសារដែលពាក់ព័ន្ធនឹងប្រធានបទនេះ ដើម្បីជាគ្រឹះសម្រាប់ការបកស្រាយនូវចំណោទបញ្ហាខាងលើនេះ ត្រូវបានធ្វើឡើងដោយប្រើប្រាស់នូវវិធីសាស្ត្រមួយចំនួនដូចជា៖

- ការស្រាវជ្រាវតាមរយៈវិធានគតិយុត្តដែលព្រះរាជាណាចក្រកម្ពុជាយើងមាន ដូចជា រដ្ឋធម្មនុញ្ញ ក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ជាអាទិ៍។
- ការស្រាវជ្រាវតាមរយៈការអានសៀវភៅដែលបានបោះពុម្ពផ្សាយ ដែលភាគច្រើនបោះពុម្ពដោយក្រសួងយុត្តិធម៌ (សេចក្តីកំណត់ចំពោះមាត្រានីមួយនៃក្រមរដ្ឋប្បវេណី និងសេចក្តីពន្យល់ក្រមរដ្ឋប្បវេណី ព្រមទាំងឯកសារសិក្ខាសាលានានាក្នុងក្របខណ្ឌកម្មវិធីអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ និងយុត្តិធម៌) និងសេចក្តីសម្រេចរបស់តុលាការ។
- ការសាកសួរ លោក លោកស្រីសាស្ត្រាចារ្យ និងមន្ត្រីអនុវត្តច្បាប់ដូច មេធាវី និងក្រឡាបញ្ជីចំពោះបញ្ហាទាក់ទងទៅនឹងការអនុវត្តនូវរបបអាហារកាតព្វកិច្ច។
- តាមរយៈការផ្សាយតាមទូរទស្សន៍ ពីកម្មវិធីនាទីច្បាប់ របស់ស្ថានីយ៍ទូរទស្សន៍ BTV វីដេអូផ្សេងៗទៀតទាក់ទងនឹងការយល់ដឹងផ្នែកច្បាប់ និងកម្មវិធីរបស់វិទ្យុផងដែរ ដែលបានបកស្រាយដោយ អ្នកវិជ្ជាជីវៈផ្នែកច្បាប់។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះចែកជា ៣ជំពូក។ ជំពូកទី១ បង្ហាញពីសញ្ញាណទូទៅនៃការបង្កើតឡើងនៃរបបអាហារកាតព្វកិច្ច។ រីឯ ជំពូកទី២សិក្សាទៅលើការកំណត់ពីអាហារកាតព្វកិច្ច ដែលមានវត្តមានលើក្នុងបទដ្ឋានគតិយុត្តនៃកម្ពុជា។ ចំណែកឯ ជំពូកទី៣ធ្វើការលើកឡើងពីគុណសម្បត្តិ គុណវិបត្តិ និងបកស្រាយពីបញ្ហាប្រឈមនៃការអនុវត្ត។ បន្ថែមពីនេះ នៅចុងបញ្ចប់សារណានេះ មានការបន្ថែមនូវសេចក្តីសន្និដ្ឋាន និងអនុសាសន៍ក្នុងការកែទម្រង់លើបញ្ហាមួយចំនួន ដើម្បីបង្កើននូវភាពងាយស្រួលក្នុងស្វែងយល់ពីការអនុវត្តនូវរបបអាហារកាតព្វកិច្ចនេះ ឲ្យមានប្រសិទ្ធភាពក្នុងបរិបទកម្ពុជា។

# ជំពូកទី១

# សញ្ញាណនៃរបបអាហារកាតព្វកិច្ច

## ១.១. និយមន័យ

តាមបែបអក្សរសាស្ត្រខ្មែរ ពាក្យថា អាហារកាតព្វកិច្ច ត្រូវបន្សំឡើងដោយពាក្យថា "អាហារ + កាតព្វកិច្ច"។ ផ្អែកតាមវចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត ពាក្យថា អាហារ (នាមស័ព្ទ) (សំ.បា.) មានន័យថា៖ "ជាគ្រឿងបរិភោគចម្អែតអាត្មា, ភោជន"។ ឧទាហរណ៍ ចម្អិនអាហារ, បរិភោគអាហារ។ រីឯពាក្យ កាតព្វកិច្ច (នាមស័ព្ទ) (បា.) មកពីពាក្យ ករណីយកិច្ច មានន័យថា៖ "កិច្ចដែលគួរធ្វើ, ការងារដែលត្រូវតែធ្វើ"។ អាចសរុបបានថា អាហារកាតព្វកិច្ច គឺជា គ្រឿងសម្រាប់បរិភោគប្រចាំថ្ងៃដែលមនុស្សគ្រប់រូបត្រូវបានទទួលជាចាំបាច់ ឬក៏និយាយបានម្យ៉ាងទៀតថា ជាកិច្ចការដែលត្រូវធ្វើជាចាំបាច់ដើម្បីផ្គត់ផ្គង់ការហូបចុកជាតម្រូវការប្រចាំថ្ងៃដោយខានពុំបាន។

ទោះជាត្រូវបានឲ្យនិយមន័យដោយការបន្សំពាក្យតាមបែបអក្សរសាស្ត្រខ្មែរតាមវចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត ក៏ដោយ ប៉ុន្តែដើម្បីភាពជាក់ច្បាស់នៃការប្រើប្រាស់ពាក្យតាមន័យនីតិសាស្ត្រ សន្ធានុក្រមរដ្ឋប្បវេណី បានកំណត់និយមន័យបែបនិយាមថា អាហារកាតព្វកិច្ច សំដៅលើ កិច្ច ដែលត្រូវតែបំពេញតាមច្បាប់ ឬតាមសេចក្តីសម្រេចរបស់តុលាការដែលតម្រូវឲ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្តល់នូវប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងញាតិនឹងគ្នា។

រីឯករណីយកិច្ចជួយផ្គត់ផ្គង់គ្នារបស់សហព័ទ្ធ និងការផ្គត់ផ្គង់កូនជាអនីតិជន ក៏ត្រូវផ្សារភ្ជាប់ជាមួយនឹងរបបនៃអាហារកាតព្វកិច្ចនេះដែរ។ ករណីយកិច្ចរួមរស់នឹងគ្នា សហការ និងជួយសង្គ្រោះគ្នាទៅវិញទៅមករបស់សហព័ទ្ធ ត្រូវបានកើតឡើងដោយអានុភាពនៃអាពាហ៍ពិពាហ៍ ចំណែកឯការមើលថែរក្សា អប់រំកូនជាអនីតិជននោះ ជាសិទ្ធិ និងករណីយកិច្ចរបស់អ្នកមានអំណាចមេបា។

## ១.២. ការវិវត្តន៍នៃរបបអាហារកាតព្វកិច្ច

### ១.២.១. អាហារកាតព្វកិច្ចច្បាប់ចាស់

អាហារកាតព្វកិច្ច គឺជាករណីយកិច្ចដែលជនម្នាក់ត្រូវផ្គត់ផ្គង់ដល់ជនម្នាក់ទៀតនូវជីវព្រឹត្តគឺ ចំណី អាហារ ទីស្នាក់អាស្រ័យ និងការថែទាំ។[3]

តាមខ្លឹមសារនៃច្បាប់ អាហារកាតព្វកិច្ចត្រូវបានមើលឃើញក្នុងរូបភាពដូចជា អាហារកាតព្វកិច្ចរវាងប្តីប្រពន្ធ អាហារកាតព្វកិច្ចចំពោះកូនដែលជាអនីតិជន។ ចំពោះអាហារកាតព្វកិច្ចចំពោះប្តីប្រពន្ធកើតឡើងដោយសារតែចំណងអាពាហ៍ពិពាហ៍ ហើយវាមានឥទ្ធិពលយ៉ាងខ្លាំងក្លាចំពោះទំនាក់ទំនងប្តីប្រពន្ធក្នុងចំណង

[3] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,គ្មានលេខ,ឆ្នាំ១៩២០, មាត្រា៤៧៨ ។

អាពាហ៍ពិពាហ៍ ព្រោះប្រសិនបើប្តីប្រពន្ធមិនទាន់បានបំពេញកាតព្វកិច្ចចំពោះគ្នា គឺនឹងអាចនាំឲ្យរលាយចំណង អាពាហ៍ពិពាហ៍ទៀតផង។

ការផ្តត់ផ្គង់អាហាកាតព្វកិច្ចរបស់ខ្លួនដល់កូនជាអនីតិជន កាលបើមិនត្រូវបានបំពេញ ឬបំពេញមិនពេញលេញ ក៏នឹងនាំឲ្យថ្លស់អំណាចមេបាបាត់បង់ផងដែរ។ ទំនាក់ទំនងផ្សេងមួយចំនួនទៀតដែលត្រូវមានកាតព្វកិច្ចក្នុងការផ្តត់ផ្គង់អាហារកាតព្វកិច្ចផងដែរដូចជា អាហារកាតព្វកិច្ចចំពោះឪពុកម្តាយ និងអាហារកាតព្វកិច្ចចំពោះញាតិ។ កូនទាំងឡាយ ដែលមានវ័យធំធាត់ល្មមធ្វើការចិញ្ចឹមជីវិតបានដោយខ្លួនឯង ត្រូវមានតួនាទីជួយ ផ្គត់ផ្គង់ជីវព្រឹត្តដល់ឪពុកម្តាយ ឬដល់បុព្វញាតិឯទៀតដែលទ័លក្រ។[4] ក្រៅពីកូនបង្កើត កូនប្រសាប្រុសស្រីក៏ត្រូវមានកាតព្វកិច្ចក្នុងការជួយចិញ្ចឹមបីបាច់ថែរក្សា និងផ្គត់ផ្គង់នូវជីវព្រឹត្តដល់ឪពុកម្តាយក្មេក រួមទាំងបុព្វញាតិដែលខ្វះខាត ទីទ័លក្រ ដូចកូនបង្កើតផងដែរ។

យ៉ាងណាមិញ ក្នុងករណីដែលឪពុកម្តាយបានលាចាកលោកទៅ ហើយបន្សល់នូវបច្ឆាញាតិដែលជាអនីតិជនដែលមិនទាន់អាចមានមុខរបរចិញ្ចឹមខ្លួនឯងបាន បន្ទុកក្នុងការផ្គត់ផ្គង់អាហារកាតព្វកិច្ចត្រូវធ្លាក់ជាបន្ទុករបស់បុគ្គលដែលជាបុព្វញាតិផ្សេងទៀតដែលមានលទ្ធភាពរកស៊ីចិញ្ចឹមខ្លួនឯងជាអ្នកផ្គត់ផ្គង់ រហូតដល់គ្រប់នីតិភាព។

### ១.២.២. អាហារកាតព្វកិច្ចសម័យបច្ចុប្បន្ន

អាហារកាតព្វកិច្ច គឺជាជំនួយផ្នែកហិរញ្ញវត្ថុ ដល់បុគ្គលដែលមិនអាចទ្រទ្រង់ជីវភាពខ្លួនឯងបាន។[5] ក្នុងន័យនេះ បានកំណត់ថា ជនដែលទទួលជំនួយក្នុងការទ្រទ្រង់ ឬជនដែលត្រូវការអាហារកាតព្វកិច្ច ត្រូវបានគេឲ្យឈ្មោះថា ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ចំណែកដែលជនដែលត្រូវផ្គត់ផ្គង់ នូវជំនួយហិរញ្ញវត្ថុ ឬទ្រទ្រង់នូវរបបជីវព្រឹត្ត ដែលគេហៅថាអាហារកាតព្វកិច្ច ត្រូវបានគេហៅថា ជនដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច។

នៅក្នុងច្បាប់ថ្មី ពាក្យ អាហារកិច្ច ត្រូវបានកែប្រែមកជាពាក្យ អាហារកាតព្វកិច្ច វិញ[6] បានកំណត់យ៉ាងជាក់លាក់នូវប្រភេទអាហារកាតព្វកិច្ចជា ពីរប្រភេទដាច់ពីគ្នា គឺ អាហារកាតព្វកិច្ចឯកជន និង អាហារកាតព្វកិច្ចសាធារណៈ។ បញ្ញត្តិនៃច្បាប់ថ្មីនេះបានបែងចែកអាហារកាតព្វកិច្ចឯកជនរួមមាន អាហារកាតព្វកិច្ចចំពោះសហព័ទ្ធ គឺជាអានុភាពនៃអាពាហ៍ពិពាហ៍[7], អាហារកាតព្វកិច្ចដែលផ្តល់ដោយឪពុកម្តាយមកកាន់កូនដែលជាអនីតិ

---

[4] ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,គ្មានលេខ,ឆ្នាំ១៩២០,មាត្រា៤៨០។

[5] ក្រុមការងារនៃគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រម, សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណីភាគ៣ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០១៧), ១៧៥។

[6] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកប/០៥១១/០០៧, ៣១ ឧសភា ២០១១, មាត្រា៨១។

[7] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៦៦ ដល់មាត្រា៩៧១។

ជន ដែលកើតចេញពីអានុភាពនៃអំណាចមេបា[8] ហើយលើសពីនេះទៅទៀត អាហារកាតព្វកិច្ចក៏អាចត្រូវបានកើតឡើងផងដែរនៅក្នុងទំនាក់ទំនងលោហិត។[9] ឪពុកឬម្ដាយដែលលែងលះគ្នា ត្រូវជួយផ្គត់ផ្គង់ជួយបីបាច់រក្សា ជួយផ្ដល់សោហ៊ុយ អប់រំ និងរៀនសូត្រដល់កូនតាមលទ្ធភាពរបស់ខ្លួន។ កម្រិតអាហារកិច្ចដែលត្រូវឱ្យទៅកូនត្រូវសំរេចតាមការព្រមព្រៀងនៃសហព័ទ្ធដែលលែងលះគ្នា។ ក្នុងករណីដែលគូភាគីទាំងសងខាង មិនឯកភាពគ្នា តុលាការត្រូវសំរេច ដោយផ្អែកទៅតាមលទ្ធភាពរបស់សហព័ទ្ធម្នាក់ៗ។ អាហារកិច្ចត្រូវផ្ដល់ឱ្យកូនរហូត ដល់កូនមាននីតិភាព។[10] ចំណែកឯក្នុងករណីលែងលះគ្នា ភាគីដែលគ្មានកំហុស ហើយខ្វះខាត អាចស្នើសុំអាហារកិច្ចពីភាគម្ខាងទៀតបាន ដែលត្រូវតែជួយឧបត្ថម្ភទៅតាមលទ្ធភាពរបស់ខ្លួន រីឯការកម្រិតអាហារកិច្ចត្រូវសំរេចតាមការយល់ព្រមរបស់គូភាគីទាំងសងខាង។[11]

[8] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៣៤ ដល់មាត្រា ១០៤០។

[9] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៤០ ដល់មាត្រា ១១៤៤។

[10] ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ក្រ. , ១៧ កក្កដា ១៩៨៩, មាត្រា៧៥។

[11] ច្បាប់ស្ដីពីអាពាហ៍ពិបាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ., ១៧ កក្កដា ១៩៨៩, មាត្រា៧៦។

# ជំពូកទី២

# ការកំណត់ពីរបបអាហារកាតព្វកិច្ច

កាលណាអាហារកាតព្វកិច្ចមានវត្តមាននៅក្នុងសង្គម ការកំណត់ពីលក្ខខណ្ឌដែលត្រូវអនុវត្តឲ្យចំគោលដៅ ឬ វត្ថុបំណង គឺជារឿងចាំបាច់បំផុត ដើម្បីធានាបាននូវការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់។ ប្រសិនបើ មានកំណត់តែពីរបបអាហារកាតព្វកិច្ច តែមិនបានកំណត់អំពីលក្ខខណ្ឌ ឬគោលការណ៍នៃការអនុវត្តទេនោះ បញ្ហានៃការអនុវត្តនឹងមានការបែកចែងតាមតំបន់នីមួយៗ មិនសង្រួមបញ្ចូលគ្នា ជាហេតុធ្វើឲ្យរដ្ឋមួយមានបែបបទអនុវត្តច្រើនយ៉ាង លើវត្ថុបំណងតែមួយ។

ទ្រឹស្តីជាហេតុផលចម្បងនាំឲ្យមានការអនុវត្ត ឬ ការណែនាំផ្លូវសម្រាប់បង្ហាញដល់អ្នកអនុវត្តតាម ប៉ុន្តែការយកមកអនុវត្តជាក់ស្តែងជារឿងមួយផ្សេងទៀត ជាពិសេសបញ្ហាខ្លះដែលនីតិករមិនបានរំពឹងទុកនឹងកើតមានឡើងស្តែងតាមរូបភាពនៃការអនុវត្ត។

## ២.១. តួអង្គក្នុងការអនុវត្ត

ដើម្បីអាចអនុវត្តបាននូវអាហារកាតព្វកិច្ច ក្រមរដ្ឋប្បវេណីបានកំណត់ពីលក្ខណៈសម្បត្តិជនដែលជាតួអង្គយ៉ាងសំខាន់ នៅក្នុងដំណើរនៃការប្រព្រឹត្តទៅនៃអាហារកាតព្វកិច្ច ព្រោះជាការដើរតួដើម្បីបំពេញនូវលក្ខខណ្ឌទម្រង់នៃអាហារកាតព្វកិច្ចដែលមានដូចជា ញាតិភាព សហព័ទ្ធ និង កូនជាអនីតិជន។

### ២.១.១. ញាតិភាព

ញាតិ សំដៅដល់បុគ្គលរូបណាដែលមានទំនាក់ទំនងលោហិតនឹងគ្នាក្នុង ៦ ថ្នាក់ (ញាតិលោហិត) ប្តីប្រពន្ធដែលបានរៀបអាពាហ៍ពិពាហ៍នឹងគ្នាស្របតាមច្បាប់ (សហព័ទ្ធ) និងបងប្អូនសាច់ថ្លៃទាំងខាងប្តី ទាំងខាងប្រពន្ធក្នុង ៣ ថ្នាក់ (ញាតិពន្ធ) ។ គ្រប់បុគ្គលដែលមានទំនាក់ទំនងដូចខាងដើម ត្រូវបានច្បាប់ចាត់ទុកថា គឺជាញាតិ។[12] ជាការពិតណាស់បុគ្គលដែលកំណត់ខាងលើ គឺជាបុគ្គលដែលស្ថិតក្នុងទំហំញាតិដែលត្រូវបានទទួលស្គាល់ដោយច្បាប់។ ប៉ុន្តែនៅក្នុងការអនុវត្តអាហារកាតព្វកិច្ច ក្រមរដ្ឋប្បវេណីមិនបានកំណត់នូវលក្ខណៈសម្បត្តិញាតិក្នុងទំហំដែលត្រូវផ្គត់ផ្គង់ទេ ដោយហេតុថា អាហារកាតព្វកិច្ច គឺជាកិច្ច ដែលត្រូវតែបំពេញតាមច្បាប់ ដែលតម្រូវឲ្យបុគ្គលម្នាក់ ឬច្រើននាក់ផ្តល់នូវប្រាក់ ឬទ្រព្យដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅដល់បុគ្គលផ្សេងទៀតដែលមានទំនាក់ទំនងញាតិនឹងគ្នា។

មូលហេតុដែលនាំឲ្យមានការកំណត់ពីញាតិ គឺដើម្បីបង្ហាញឲ្យដឹងថា បុគ្គលរូបណាខ្លះដែលអាចទទួលបាននូវអាហារូបត្ថម្ភសម្រាប់ជាប្រយោជន៍ ក្នុងការទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួននោះ។ ចំណុចនេះ

[12] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៩៣៨។

ផ្តោតសំខាន់លើអាហារកាតព្វកិច្ចដែលកើតចេញពីចំណងញាតិ ហេតុដូចនេះ ញាតិដែលកំណត់ គឺសំដៅដល់បុគ្គលដែលមានសិទ្ធិទាមទារបុគ្គលដែលមានករណីយកិច្ចផ្គត់ផ្គត់ និង ទំនាក់ទំនងនៃញាតិភាព ។

### ២.១.១.១. បុគ្គលដែលមានសិទ្ធិក្នុងការទាមទារអាហារកាតព្វកិច្ច

ជនដែលមិនអាចទ្រទ្រង់ជីវភាពខ្លួនឯងក្នុងកម្រិតអប្បបរមាបាន ហើយមានសិទ្ធិទាមទារអាហារកាតព្វកិច្ចពីញាតិរបស់ខ្លួនបាន ហៅថា ជនដែលមានសិទ្ធិទទួលបានអាហារកាតព្វកិច្ច។[13]

ជនដែលអាចមានសិទ្ធិក្នុងការទាមទារអាហារកាតព្វកិច្ចបាន លុះត្រាតែត្រូវបានបំពេញតាមលក្ខខណ្ឌញាតិ សំដៅដល់ជនដែលមានទំនាក់ទំនងញាតិនឹងគ្នាដែលគ្មានលទ្ធភាព ឬធនធានគ្រប់គ្រាន់ ហើយដែលមានតម្រូវការមូលដ្ឋានចាំបាច់ដែលខានមិនបានដូចជា អាហារ សម្លៀកបំពាក់ ទីជម្រក សុខភាព និងការអប់រំជាមូលដ្ឋាន ជាដើម។[14] ប៉ុន្តែប្រសិនបើជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចមានច្រើននាក់ ត្រូវកំណត់ជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់ម្នាក់ ឬ ច្រើននាក់តាមការពិភាក្សា ឬ សម្រេចដោយតុលាការ ដោយពិចារណាទៅលើលទ្ធភាព ទ្រព្យធន អាយុ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនដែលមានករណីយកិច្ច ហើយរាប់បញ្ចូលទាំងទំនាក់ទំនងបុគ្គល និងស្ថានភាពផ្សេងៗទៀត។[15]

### ២.១.១.២. បុគ្គលដែលមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច

ជនដែលត្រូវផ្តល់អាហារកាតព្វកិច្ច ត្រូវធ្វើការផ្គត់ផ្គង់ជាសម្ភារៈ ឬ ហិរញ្ញវត្ថុតាមមធ្យោបាយសមស្របណាមួយ ទៅឲ្យជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ច ក្នុងករណីដែលជននោះអលទ្ធភាព មិនអាចចិញ្ចឹមខ្លួនឯងបាន សម្រាប់តម្រូវការជីវភាពរស់នៅជាអប្បបរមា តាមលទ្ធភាពដែលខ្លួនអាចជួយបាន ដោយមិនអាចក្លាយជាបន្ទុកដែលនាំឲ្យខ្លួនត្រូវធ្លាក់ខ្លួនក្រីក្រឡើយ។ ទោះជាយ៉ាងណាក៏ដោយ មិនមែនមានន័យថា គ្រប់ទំនាក់ទំនងញាតិទាំងអស់ សុទ្ធតែមានករណីកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចនោះទេ។ ជាទូទៅញាតិមួយចំនួនត្រូវបានច្បាប់បញ្ញតិតាមលំដាប់ជាជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច តែនៅក្នុងករណីខ្លះ តុលាការមានសិទ្ធិក្នុងការតែងតាំងជនផ្សេងទៀត ជាជនដែលមានករណីយកិច្ចត្រូវផ្គត់អាហារកាតព្វកិច្ចបានផងដែរ។[16]

[13] ក្រុមការងារនៃគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រម, សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណីភាគ៣ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០១៧), ៣៦។

[14] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៤០។

[15] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា១១៤១។

[16] ក្រុមការងារនៃគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រម, សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណីភាគ៣ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០១៧), ៣៩។

ប្រសិនបើជនដែលមានករណីយកិច្ចត្រូវផ្គត់ផ្គង់មានច្រើននាក់ ជននោះត្រូវកំណត់ជាក់លាក់ ដើម្បីឲ្យទទួលបន្ទុកអាហារកាតព្វកិច្ច តាមរយៈការពិភាក្សាហើយបើការពិភាក្សាទទួលបរាជ័យ តុលាការត្រូវសម្រេចដោយការពិចារណាទៅលើលទ្ធភាព ទ្រព្យធន អាយុ ស្ថានភាពផ្លូវកាយ និងផ្លូវចិត្តរបស់ជនដែលមានករណីយកិច្ច ហើយរាប់បញ្ចូលទាំងទំនាក់ទំនងបុគ្គល និងស្ថានភាពផ្សេងទៀតផងដែរ។

**២.១.១.៣. ទំនាក់ទំនងនៃញាតិភាព**

ញាតិគឺជាទំនាក់ទំនងគតិយុត្តដែលច្បាប់បានទទួលស្គាល់ និងផ្តល់នូវទំនាក់ទំនងដែលមាន លក្ខណៈពិសេសពីទំនាក់ទំនងចំពោះមនុស្សធម្មតា ដែលផ្សាភ្ជាប់ទៅនឹងទំនាក់ទំនងក្នុងសង្គមផងដែរ។ បុគ្គលដែលត្រូវបានចាត់ទុកជាញាតិ ហើយទទួលស្គាល់ដោយច្បាប់មានដូចជា ញាតិលោហិត ញាតិពន្ធ សាខាញាតិ។ បងប្អូនបង្កើត ជាមួយគ្នាគឺរួមឪពុកម្តាយគឺរួមឪពុក ម្តាយ ឬរួមតែឪពុក គឺឪពុកជាមួយគ្នាម្តាយទីទៃ ឬក៏រួមតែម្តាយ គឺម្តាយជាមួយគ្នាឪពុកទីទៃ។[17]

**ក. ញាតិដែលរស់នៅជាមួយគ្នា**

ការកំណត់អំពីញាតិដែលរស់នៅជាមួយគ្នា មិនសំដៅចំពោះញាតិក្នុងថ្នាក់ណាមួយឡើយ អ្វីដែលសំខាន់នោះគឺត្រូវស្ថិតនៅក្នុងទំហំញាតិដែលបានកំណត់[18] ញាតិណាមួយដែលរស់នៅជាមួយគ្នានោះគឺជាជនដែលមានករណីយកិច្ច និងជាជនដែលមានសិទ្ធិទាមទារអាហារកាតព្វកិច្ច បានតាមច្បាប់ដោយបញ្ញត្តិក្នុងលំដាប់ទីមួយដែលមានកាតព្វកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ប្រសិនបើជនដែលរស់នៅជាមួយនោះអលទ្ធភាពក្នុងការផ្គត់ផ្គង់ជីវភាពដោយខ្លួនឯងបាន។ ការផ្គត់ផ្គង់ដល់ញាតិដែលរស់នៅជាមួយគ្នា អាចជាញាតិដែលរស់ជាអចិន្ត្រៃយ៍ និងញាតិដែលរស់នៅជាមួយបណ្តោះអាសន្ន ។

**ក.១. ការរស់នៅជាអចិន្ត្រៃយ៍**

ការរស់នៅជាអចិន្ត្រៃយ៍ជាមួយគ្នា ភាគច្រើនគឺជាញាតិស្ថិតក្រុមគ្រួសារតែមួយដែលមានឪពុក ម្តាយ ប្តី ប្រពន្ធ ឬកូនចៅ ជាអាទិ៍ ហើយប្រសិនបើបុគ្គលណាម្នាក់ដែលរស់នៅក្រោមដំបូលផ្ទះតែមួយនេះ បានក្លាយជាបុគ្គលដែលបាត់បង់ប្រាក់ចំណូលដោយហេតុគ្មានការងារធ្វើ ឬក៏ដោយសារវ័យជរាមិនអាចប្រកបការងារបានសម្រាប់ការប្រើប្រាស់នូវតម្រូវការជីវភាពប្រចាំថ្ងៃបាននោះ ឬក៏ដោយសារជម្ងឺដែលតម្រូវឲ្យបុគ្គលគ្មានលទ្ធភាពក្នុងការស្វែងរកប្រាក់ចំណូលផ្ទាល់ខ្លួនបាន នោះកាតព្វកិច្ចដែលត្រូវផ្គត់ផ្គង់នូវតម្រូវការជីវភាពរបស់ពួកគេនឹងត្រូវក្លាយជាបន្ទុកដល់ញាតិដែលរស់នៅជាមួយគ្នាជាអ្នករ៉ាប់រង។ ការទទួលបន្ទុកនេះមិនត្រូវបានកំណត់ពីថ្នាក់នៃញាតិឡើយ ភាពចាំបាច់ក្នុងការសម្គាល់ គឺបុគ្គលដែលមានសិទ្ធិក្នុងការទទួលអាហារកាតព្វកិច្ចគឺត្រូវស្ថិតក្នុងទំហំ

[17] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ. ,១៧ កក្កដា ១៩៨៩, មាត្រា៧៨។

[18] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៩៣៨។

ញាតិដែលត្រូវបានកំណត់ក្នុងផ្នែកខាងលើ ហើយស្ថិតក្នុងការរួមរស់ក្រោមដំបូលផ្ទះតែមួយ។ ក បានយកឪពុកម្តាយរបស់គេមករស់នៅជាមួយ ហើយ ខ ក៏បានយកឪពុកម្តាយ និងប្អូនពៅរបស់គេមករស់នៅជាមួយផងដែរ។ ដោយហេតុថា ឪពុកម្តាយរបស់ ក ពួកគាត់មានវ័យចាស់ជរា មិនអាចប្រកបការងារបាន តែឪពុកម្តាយរបស់ ខ មានការងារធ្វើជាធម្មតា តែជាអកុសល ឪពុកម្តាយរបស់ ខ បានគ្រោះថ្នាក់ចរាចរណ៍ បានបណ្តាលឲ្យពួកគាត់បាត់បង់សមត្ថភាពក្នុងការធ្វើការ ហេតុនេះហើយ ពួកគាត់មិនអាចរកប្រាក់ចំនួលសម្រាប់តម្រូវការរបស់គាត់ និងផ្គត់ផ្គង់ការសិក្សារបស់កូនពៅរបស់គាត់បានទេ ហេតុនេះហើយបន្ទុកចំណាយត្រូវធ្លាក់មកលើ ក តែបើនិយាយពីទំហំញាតិ ក នឹងឪពុកម្តាយរបស់ ខ ត្រូវជាឪពុកម្តាយក្មេក និងរវាង ក និងប្អូនពៅរបស់ ខ ត្រូវបងប្អូនថ្លៃ ។

**ក.២. ការរស់នៅជាបណ្តោះអាសន្ន**

ក្នុងពេលដែលអ្នកមានសិទ្ធិទទួលអាហារកាតព្វកិច្ចជួបនូវហេតុការណ៍ណាមួយ ឬបុព្វហេតុនៃប្រធានសក្តិ ដែលធ្វើឲ្យបុគ្គលនោះមិនអាចរស់នៅក្នុងលំនៅឋានរបស់ខ្លួនបាន និង អលទ្ធភាពក្នុងការផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរបស់ខ្លួនជាបណ្តោះអាសន្ន អ្នកដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចអាចស្នើសុំជំនួយ ក្នុងការស្នាក់នៅជាមួយនឹងញាតិរបស់ខ្លួនបាន ដោយតម្រូវឲ្យញាតិដែលមានលទ្ធភាពនោះទទួលរ៉ាប់រងបន្ទុកចំណាយសម្រាប់ការរស់នៅជាបណ្តោះអាសន្ន ហើយការស្នើសុំក្នុងការផ្គត់ផ្គង់នូវអាហារកាតព្វកិច្ចជាបណ្តោះអាសន្នមិនកំណត់ពីលំដាប់នៃញាតិឡើយ ដោយធ្វើឡើងតាមការព្រមព្រៀងទទួលឲ្យស្នាក់នៅ។ បុគ្គលដែលទទួលអ្នកដែលមានសិទ្ធិ នឹងប្រែក្លាយជាជនដែលមានលំដាប់ទីមួយ[19] ដែលតម្រូវឲ្យផ្តល់នូវការផ្គត់ផ្គង់ដល់ញាតិដែលខ្លួនទទួលឲ្យស្នាក់អាស្រ័យជាបណ្តោះអាសន្ន។

ប្រសិនបើជនណាម្នាក់ទទួលយកអ្នកដែលមានជីវភាពខ្វះខាតឲ្យមករស់នៅជាមួយនឹងផ្គត់ផ្គត់អាហារដល់គេ គឺជាអំពើសប្បុរសធម៌ តែមិនមែនមែនជារបបនៃអាហារកាតព្វកិច្ចឡើយ។ ជនដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចនេះត្រូវមានករណីយកិច្ចចងភ្ជាប់ដោយច្បាប់ ចំណែកឯការទទួលយកជនក្រីក្រមករស់នៅជាមួយនេះមិនត្រូវបានចងភ្ជាប់ករណីយកិច្ចដោយច្បាប់ឡើយ។ ជាឧទាហរណ៍ ក ត្រូវជាបងថ្លៃរបស់ ខ ដែលរស់នៅភូមិជាមួយគ្នា។ នៅក្នុងរដូវវស្សា ទឹកជំនន់បានកើនឡើង ហើយថាធ្វើឲ្យផ្ទះរបស់ ក បានបាក់ស្រុតបាក់ទៅ។ បើគិតតាមលំដាប់នៃជនដែលត្រូវមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ខ គឺមិនមែនលំដាប់មុនឡើយ តែដោយសារថាកូនរបស់គាត់រស់នៅឯបរទេស ក បានមកស្នាក់នៅជាមួយ ខ ដែលត្រូវជាប្អូនថ្លៃបណ្តោះអាសន្នរហូតដល់ទឹកជំនន់បានស្រកទៅវិញ។ ខ ត្រូវមានកាតព្វកិច្ចផ្គត់ផ្គង់ដល់ ក ដែលត្រូវជាញាតិនោះ ក្នុងពេលដែល

[19] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៤០ កថាខណ្ឌ១, វាក្យខណ្ឌ១។

គាត់មិនអាចមានលទ្ធភាពទ្រទ្រង់ដោយស្ថានភាពរស់នៅដោយឯករាជ្យបាន ព្រោះពួកគេជាញាតិដែលរស់នៅជាមួយគ្នា ដែលច្បាប់បានកំណត់ជា ជនដែលមានលំដាប់ទីមួយ។

### ២.១.២. ញាតិលោហិតខ្សែផ្ទាល់

ញាតិខ្សែផ្ទាល់ គឺជាទំនាក់ទំនងខ្សែលោហិតដែលត្រង់ផ្ទាល់។ ញាតិ ខ្សែផ្ទាល់ រាប់បញ្ចូលផងដែរដូចជាកូនបង្កើត (កូនមានខាន់ស្លា និងកូនឥតខាន់ស្លា) ឪពុកម្តាយបង្កើត ឬឪពុកម្តាយចិញ្ចឹម។ ញាតិជួរខ្សែផ្ទាល់នោះ គឺអ្នកដែលកើតគ្នាតពី ១ ទៅ ១ តាមលំដាប់ គឺឪពុក កូន ចៅ ចៅទួត ។ល។ ញាតិជួរខ្សែផ្ទាល់ក្នុង៦ថ្នាក់ចែកចេញជា បុព្វញាតិផ្ទាល់ និង បច្ឆាញាតិផ្ទាល់។

ញាតិត្រូវមានករណីយកិច្ចជួយផ្គត់ផ្គង់ចំពោះគ្នាទៅវិញទៅមក ក្នុងករណីដែលញាតិណាមួយ អលទ្ធភាពក្នុងការគាំពារការរស់នៅរបស់ខ្លួន ដោយមូលហេតុណាមួយដែលអាចទទួលយកបាន។ ប៉ុន្តែទំហំនៃការអនុវត្តពុំត្រូវបានកំណត់ពីកម្រិតឡើយ គឺអាស្រ័យលើកការពិភាក្សាគ្នា ឬតាមការសេចក្តីសម្រេចរបស់តុលាការតែប៉ុណ្ណោះ។

ញាតិដែលស្ថិតក្នុងទំនាក់ទំនងញាតិលោហិតខ្សែផ្ទាល់ ក៏ត្រូវបានកំណត់ជាជនដែលមានសិទ្ធិ និងមានករណីយកិច្ចក្នុងការអនុវត្តនូវរបបអាហារកាតព្វកិច្ច។ ជនដែលមានទំនាក់ទំនងញាតិលោហិតនឹងគ្នាដែលមានញាតិខាងលើ ៦ថ្នាក់ (បុព្វញាតិ) និង ញាតិខាងក្រោម ៦ថ្នាក់ (បច្ឆាញាតិ) ដែលចាប់ផ្តើមរាប់ពីអ្នកបង្កើតរួម គឺជាជនដែលច្បាប់បានកំណត់ថា បុគ្គលដែលស្ថិតក្នុងទំនាក់ទំនងបែបនេះគឺមានសិទ្ធ និង ករណីយកិច្ចក្នុងផ្គត់ផ្គង់គ្នាក្នុងគ្រាដែលញាតិរបស់ខ្លួនមិនអាចផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួនបាន។

### ២.១.៣. បងប្អូនបង្កើត

កូនដែលកើតពីឪពុកម្តាយជាមួយគ្នា គឺរួមឪពុកម្តាយគឺរួមឪពុក ម្តាយ ឬរួមតែឪពុក គឺឪពុកជាមួយគ្នាម្តាយទីទៃ ឬ ក៏រួមតែម្តាយ គឺម្តាយជាមួយគ្នាឪពុកទីទៃ ក៏ត្រូវមានជាប់ករណីយកិច្ចជួយផ្គត់ផ្គង់អាហារកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកដូចគ្នា។ ឧទាហរណ៍ថា ក ត្រូវជាបងថ្លៃរបស់ ខ ដែលរស់នៅភូមិជាមួយគ្នា។ នៅក្នុងរដូវវស្សា ទឹកជំនន់បានកើនឡើង ហើយថាធ្វើឲ្យផ្ទះរបស់ ក បានបាក់ស្រុតបានទៅ។ បើគិតតាមលំដាប់នៃជនដែលត្រូវមានករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ខ គឺមិនមែនលំដាប់មុនឡើយ តែដោយសារថាកូនរបស់គាត់រស់នៅឯបរទេស ហេតុនេះ ក បានមកស្នាក់នៅជាមួយ ខ ដែលត្រូវជាប្អូនថ្លៃបណ្តោះអាសន្នរហូតដល់ទឹកជំនន់បានស្រកទៅវិញ ខ និងសហព័ទ្ធរបស់គេ ត្រូវមានកាតព្វកិច្ចផ្គត់ផ្គង់ដល់ ក ដែលត្រូវជាញាតិនោះ ក្នុងពេលដែលគាត់មិនអាចមានលទ្ធភាពទ្រទ្រង់ដោយស្ថានភាពរស់នៅដោយឯករាជ្យបាន។

### ២.១.៤. ញាតិដែលកំណត់ដោយសេចក្ដីសម្រេចរបស់តុលាការ

ជាគោលការណ៍ ជនដែលមានករណីយកិច្ចត្រូវផ្ដល់ផ្គង់អាហារកាតព្វកិច្ចគឺ ទី១ ញាតិដែលរស់នៅជាមួយគ្នា ទី២ ញាតិលោហិតខ្សែផ្ទាល់ និង ទី៣ បងប្អូនបង្កើត ហើយក្រៅពីអ្នកទាំងនោះ តុលាការអាចសម្រេចឲ្យញាតិនៅក្នុងថ្នាក់ទី៣ និង ញាតិពន្ធក្រោយមរណៈភាពនៃសហព័ទ្ធណាម្ខាង ទទួលបន្ទុកករណីយកិច្ចអាហារកាតព្វកិច្ចបានប្រសិនបើមានស្ថានភាពពិសេស[20] ។

#### ២.១.៤.១. ញាតិក្នុងថ្នាក់ទី៣

ក្នុងករណីជនដែលស្ថិតនៅក្នុងរង្វង់ញាតិថ្នាក់ទី៣ មិនត្រូវបានជាប់កាតព្វកិច្ចតាមច្បាប់ឡើយ ច្បាប់បានកំណត់យកជនដែលមានករណីយកិច្ចផ្ដល់ផ្គង់តាមលំដាប់រួចទៅហើយ ដើម្បីបង្គាប់បង្ហាញដល់ជនដែលមានសិទ្ធិក្នុងការទាមទារអាហារកាតព្វកិច្ច អាចប្រើប្រាស់សិទ្ធិក្នុងការទាមទាររបស់ខ្លួនឲ្យត្រឹមត្រូវ និងបញ្ចៀសការប្រើប្រាស់សិទ្ធិដោយមិនសមហេតុផល។ តុលាការក៏អាចចេញសេចក្ដីសម្រេចបង្គាប់ឲ្យជនដែលស្ថិតក្នុងទំហំញាតិថ្នាក់ទី៣ ក្នុងការទទួលបន្ទុកអាហារកាតព្វកិច្ចចំពោះញាតិរបស់ខ្លួនបាន ដោយផ្អែកលើ ជនដែលមានសិទ្ធិទាមទារអាហារកាតព្វកិច្ចមិនមានញាតិដែលកំណត់ដោយច្បាប់ និងស្ថិតក្នុងទំហំញាតិថ្នាក់ទី៣ ជាមួយជនដែលករណីយកិច្ចត្រូវផ្ដល់ផ្គង់អាហារកាតព្វកិច្ចផងដែរ តាមការស្នើសុំរបស់ជនដែលមានសិទ្ធិបាន។

##### ក. ករណីគ្មានញាតិដែលកំណត់ដោយច្បាប់

ជារឿងចាំបាច់មួយដើម្បីកំណត់បានថា ជនដែលសិទ្ធិស្ថិតនៅក្នុងញាតិថ្នាក់ទី៣ ត្រូវទទួលបន្ទុករ៉ាប់រងអាហារកាតព្វកិច្ចដល់អ្នកដែលមានសិទ្ធិក្នុងការទាមទារ កាលណាជនដែលត្រូវបានកំណត់ដោយច្បាប់បានអវត្តមាន ឬបាត់ខ្លួន ដែលមិនអាចបំពេញនូវតម្រូវការតាមច្បាប់បាន។ បុគ្គលដែលមានសិទ្ធិអាចធ្វើការស្នើសុំទៅតុលាការបានដើម្បីឲ្យបុគ្គលដែលស្ថិតក្នុងទំហំញាតិថ្នាក់ទី៣ ធ្វើការរ៉ាប់រងចំពោះខ្លួនបាន ដោយហេតុថាញាតិដែលស្ថិតក្នុងថ្នាក់ទី៣ មិនត្រូវចងកាតព្វកិច្ចដោយច្បាប់ទេ ការពិភាក្សាក្នុងការផ្ដល់ផ្គង់អាចមិនសូវមានប្រសិទ្ធភាពប៉ុន្មានទេ ព្រោះទំនាក់ទំនងញាតិហាក់បីដូចជារៀងឆ្ងាយបន្តិច។

ច្បាប់មិនបានបញ្ញត្តិឲ្យជនដែលស្ថិតក្នុងញាតិថ្នាក់ទី៣ ទទួលបន្ទុករ៉ាប់រងអាហារកាតព្វកិច្ចតាមច្បាប់ឡើយ ដែលជាការលើកលែងនៃលំដាប់នៃទំហំញាតិដែលកំណត់ដោយច្បាប់ ព្រោះបុគ្គលដែលមានករណីយកិច្ចអនុវត្តរបបនៃអាហារកាតព្វកិច្ចត្រូវអនុវត្តក្រោមសេចក្ដីសម្រេចរបស់តុលាការ តាមពាក្យសុំរបស់

[20] ស្ថានភាពពិសេស គឺករណីដែលគ្មានញាតិដែលកំណត់ក្នុងកថាខណ្ឌទី១ មាត្រា ១១៤០ ឬមានញាតិដែលបានកំណត់ដូចខាងដើមនេះដែរ ប៉ុន្តែមិនអាចផ្ដត់ផ្គង់អាហារកាតព្វកិច្ចបាន ឬប្រសិនបើបើផ្ដត់ផ្គង់បណ្ដាលឲ្យធ្លាក់ខ្លួនក្រ ឬញាតិដែលមានកំណត់ខាងលើនេះមិនអាចទំនាក់ទំនងបាន ឬបាត់ខ្លួន។

អ្នកដែលមានសិទ្ធិ ដោយតុលាការបង្គាប់ឲ្យញាតិក្នុងថ្នាក់ទី៣ ទទួលបន្ទុកករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចបាន។[21]

### ២.១.៤.២. ញាតិពន្ធក្រោយមរណៈភាពនៃសហព័ទ្ធណាម្ខាង

អាពាហ៍ពិពាហ៍ដែលត្រូវបានរំលាយដោយសារមរណៈភាពរបស់សហព័ទ្ធណាម្ខាង អាហារកាតព្វកិច្ចរវាងញាតិ នៅតែមានអត្ថិភាពរវាងសហព័ទ្ធដែលនៅរស់ ជាមួយនឹងញាតិរបស់សហព័ទ្ធដែលទទួលមរណៈភាពដដែល ដោយសារករណីជាច្រើនដែលសហព័ទ្ធដែលនៅរស់ នៅតែបន្តស្នាក់នៅជាមួយគ្រួសាររបស់សហព័ទ្ធដែលទទួលមរណៈភាព និង មើលថែទាំឪពុកម្ដាយរបស់សហព័ទ្ធដែលទទួលមរណៈភាព ទើបនាំឲ្យមានការសម្រេចថា ទុកឲ្យសហព័ទ្ធដែលនៅរស់ជាអ្នកសម្រេចអំពីការរំលត់ទំនាក់ទំនងញាតិ លើកលែងតែ សហព័ទ្ធដែលនៅរស់ បានរៀបអាពាហ៍ពិពាហ៍ថ្មី ឬបង្ហាញឆន្ទៈផ្ដាច់ទំនាក់ទំនងញាតិពន្ធតាមផ្លូវតុលាការ។[22]

ប្រសិនបើសហព័ទ្ធដែលនៅរស់បានរៀបអាពាហ៍ពិពាហ៍ថ្មី ទំនាក់ទំនងញាតិរបស់សហព័ទ្ធថ្មីនឹងកើតមានឡើង ដែលនាំឲ្យមានភាពស្មុគស្មាញ ទើបតម្រូវឲ្យរំលត់នូវញាតិភាពរបស់សហព័ទ្ធចាស់ចោល។ ការរំលត់នូវញាតិភាព គឺជាលក្ខខណ្ឌនៃការផ្ដាច់នូវទំនាក់ទំនងអាហារកាតព្វកិច្ចដែលមានចំពោះញាតិផងដែរ។ ឧទាហរណ៍ថា ប្រសិនបើសហព័ទ្ធដែលនៅរស់មិនទាន់រៀបអាពាហ៍ពិពាហ៍ថ្មី តែធ្វើការបង្ហាញឆន្ទៈផ្ដាច់ចំណងញាតិភាពរបស់ញាតិពន្ធរបស់សហព័ទ្ធចាស់ដោយទុច្ចរិត ដើម្បីរួចផុតពីកាតព្វកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច ហើយធ្វើឲ្យញាតិពន្ធនោះមិនអាចផ្គត់ផ្គង់ជីវភាពរបស់ខ្លួនបាននោះនឹងទៅជាយ៉ាងណា? តុលាការអាចធ្វើការពិនិត្យ និងសម្រេចថាគួរអនុញ្ញាតឲ្យសហព័ទ្ធដែលនៅរស់អាចផ្ដាច់ចំណងញាតិភាពបានដែរទេ ប្រសិនបើសហព័ទ្ធដែលនៅរស់នោះមានការគេចវេសមិនអនុវត្តនូវករណីយកិច្ចដោយទុច្ចរិត តុលាការអាចសម្រេចមិនឲ្យផ្ដាច់ចំណងកាតព្វកិច្ចបាន។

### ២.១.៥. សហព័ទ្ធ

តើសហព័ទ្ធគឺជាអ្នកណា? តើអនីតិសង្វាសអាចចាត់ឬ រាប់បញ្ចូលថាជាសហព័ទ្ធដែរឬទេ?

មុននឹងឈានដល់ការពន្យល់បកស្រាយឱ្យកាន់តែស៊ីជម្រៅអំពីទំនាក់ទំនងនេះ ជាបឋមគឺសំខាន់បំផុតនោះគឺត្រូវសិក្សាស្វែងយល់ពីអត្ថន័យនៃពាក្យគន្លឹះជាមុនសិនមួយចំនួនជាមុនសិន។ ពាក្យថា សហព័ទ្ធ សំដៅទៅលើប្ដី ឬប្រពន្ធ ឬទាំងប្ដី ទាំងប្រពន្ធ ដែលទទួលបាននូវ ឋានៈជា សហព័ទ្ធនេះក្រោយពេលបានធ្វើការចុះសំបុត្រអាពាហ៍ពិពាហ៍យ៉ាងត្រឹមត្រូវស្របច្បាប់។ ផ្ទុយទៅវិញប្រសិនមនុស្សពីរនាក់ពេញចិត្តក្នុងការស់នៅជាមួយគ្នាក្រោមរូបភាពអាពាហ៍ពិពាហ៍តាមប្រពៃណី អ្នកទាំងពីរនឹងត្រូវរស់នៅជាមួយគ្នាក្នុងរូបភាពជាអនីតិ

[21] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៤០(២)។

[22] ក្រុមការងារនៃគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រម, សេចក្ដីពន្យល់អំពីក្រមរដ្ឋប្បវេណីភាគ៣ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០១៧),៣៨។

សង្វាសតែប៉ុណ្ណោះ ព្រោះច្បាប់មិនបានចាត់ទុកថាជាទំនាក់ទំនងក្នុងនីតិគ្រួសារឡើយ និងមិនអាចប្រើនាមជាសហព័ទ្ធបានដូចគ្នា។

សហព័ទ្ធត្រូវមានសិទ្ធិ និងករណីយកិច្ចយ៉ាងស្របច្បាប់ ប្រសិនបើសហព័ទ្ធមិនអាចបន្តរស់នៅជាមួយគ្នាក្នុងចំណងអាពាហ៍ពិពាហ៍តទៅទៀតបាន ដោយមូលហេតុណាមួយ ដែលជាហេតុនាំឲ្យឈានដល់ការលែងលះគ្នា នាំឲ្យសិទ្ធិ និងករណីយកិច្ចក៏ត្រូវបានបញ្ចប់។ ប៉ុន្តែសហព័ទ្ធក៏អាចនៅមានជាប់ករណីយកិច្ចដទៃទៀតត្រូវបំពេញ ដោយមូលហេតុនៃការសុំលែងលះកើតឡើង ក្នុងករណីដែលភាគីដែលគ្មានកំហុស ហើយខ្វះខាតអាចស្នើសុំអាហារកាតព្វកិច្ចពីភាគីម្ខាងទៀតបាន[23] ដែលនាំឱ្យភាគីម្ខាងទៀតត្រូវជាប់ជាមួយចំណងកាតព្វកិច្ចនៃការផ្គត់ផ្គង់នូវរបបអាហារកាតព្វកិច្ចដល់ភាគីដែលខ្វះខាត ប្រសិនបើមានការទាមទារ។ តុលាការអាចបង្កើនឬបន្ថយចំនួនបន្ទុកចំណាយរបស់អ្នកដែលមានកាតព្វកិច្ចផ្គត់ផ្គង់ ប្រសិនបើមានសំណូមពរពីភាគី ដោយផ្អែកទៅលើលទ្ធភាពរបស់ភាគីដែលផ្តល់ការផ្គត់ផ្គង់ ហើយកាតព្វកិច្ចនេះអាចផ្តល់ជាប្រាក់ ឬវត្ថុផ្សេងៗ។[24]

### ២.១.៦. កូនជាអនីតិជន

ក្នុងអំឡុងពេលជាប់ចំណងអាពាហ៍ពិពាហ៍ ឪពុកម្តាយមានករណីយកិច្ចស្រលាញ់កូន ចិញ្ចឹមបីបាច់ថែរក្សាកូន និងយកចិត្តទុកដាក់អប់រំកូន ព្រមទាំងបណ្តុះគំនិតកូនឲ្យស្រលាញ់ការរៀនសូត្រ ស្នេហាមាតុភូមិ មានស្មារតីសាមគ្គី អន្តរជាតិ ស្រឡាញ់ពលកម្ម គោរពទ្រព្យសម្បត្តិរដ្ឋ គោរពសិទ្ធិឯកជន និងទ្រព្យសម្បត្តិរបស់អ្នកដទៃ។[25]

កូន ទោះជាកូនមានខាន់ស្លាក្តី កូនគ្មានខាន់ស្លាក្តី ក៏មានសិទ្ធិទទួលបានការមើលថៃ និងការផ្គត់ផ្គង់ពីឪពុកម្តាយ និងករណីយកិច្ចចំពោះឪពុកម្តាយដូចៗគ្នា។[26] កូនៗទាំងអស់ត្រូវទទួលបាននូវការផ្គត់ផ្គង់អាហារកាតព្វកិច្ចពីឪពុកឬម្តាយ រហូតដល់គ្រប់នីតិភាព ឬរហូតដល់កូនមានលទ្ធភាពអាចប្រកបមុខរបរចិញ្ចឹមខ្លួនឯងបាន។ ម្យ៉ាងវិញទៀត ទំនាក់ទំនងរវាងឪពុកម្តាយចិញ្ចឹម និងកូនសុំ ដែលបង្កើតដោយកូនសុំ[27] ត្រូវបង្កើតឲ្យមាននូវសិទ្ធិ និងករណីយកិច្ចដូចគ្នា ជាមួយយនឹងសិទ្ធិ និងករណីយកិច្ចនៃទំនាក់ទំនងរវាងកូន និងឪពុកម្តាយបង្កើត។ ទំនាក់ទំនងរវាង ឪពុកម្តាយចិញ្ចឹម និងកូនសុំ ត្រូវបានចាត់ទុកថាជាទាំនាក់ទំនងញាតិលោហិតខ្សែផ្ទាល់ ហើយករណីយកិច្ច ត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច ក៏ត្រូវកើតឡើងផងដែរ។[28]

---

[23] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ. , ១៧ កក្កដា ១៩៨៩, មាត្រា៧៩(១)។

[24] ក្រុមការងារគណៈមេធាវី, សិក្ខាសាលាគណៈមេធាវី(តូច)លើកទី៥, អាហារកាតព្វកិច្ច (២៥ វិច្ឆិកា ២០១៦), ២៥៨ ។

[25] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ. , ១៧ កក្កដា ១៩៨៩, មាត្រា១១៥(១)។

[26] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ. , ១៧ កក្កដា ១៩៨៩, មាត្រា១០៤ ។

[27] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៥១ និងមាត្រា ១០២៧(១)។

[28] ក្រសួងយុត្តិធម៌៖ ការិយាល័យកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, (ភ្នំពេញ៖២០១០), មាត្រា១១៥០។

**២.២. មធ្យោបាយក្នុងការសម្រេចពីការអនុវត្ត**

ដើម្បីធានាឲ្យមានភាពល្អប្រសើរ របៀបនៃការអនុវត្តរបបអាហារកាតព្វកិច្ច ត្រូវបានកំណត់ក្នុងរូបភាព ពីរ ដូចតទៅគឺ ការពិភាក្សាក្រៅប្រព័ន្ធតុលាការ ( តាមឆន្ទៈភាគី) និងការកំណត់តាមអំណាចនៃប្រព័ន្ធតុលាការ។

តើការកំណត់តាមរបៀបនៃការពិភាក្សាក្រៅប្រព័ន្ធតុលាការ និងការកំណត់តាមបែបបទនៃអំណាចតុលាការ ខុសគ្នាដូចម្ដេចខ្លះ?

**២.២.១. ការពិភាក្សាក្រៅតុលាការ**

ការពិភាក្សា រកដំណោះស្រាយក្រៅប្រព័ន្ធតុលាការអាចធ្វើឡើងក្នុងរូបភាពច្រើនយ៉ាង ចំពោះបញ្ហានៃវិវាទឯកជន ឬហៅម្យ៉ាងទៀតថា វិវាទស៊ីវិល។ ភាគីអាចមានជម្រើសច្រើនក្នុងការជ្រើសរើស របៀបផ្សេងៗក្នុងការព្រមព្រៀងគ្នា ដើម្បីសម្រេចនូវចំណុចស្របណាមួយដែលភាគីនីមួយៗអាចទទួលយកបាន ក្នុងមុខងារជាអ្នកផ្គត់ផ្គង់ និងភាគីដែលជាអ្នកមានសិទ្ធិទទួលបាននូវការផ្គត់ផ្គង់។ ក្រមរដ្ឋប្បវេណីបានទទួលស្គាល់នូវការពិចារណាតាមឆន្ទៈរបស់គូភាគីគឺជាគោលការណ៍ជាមូលដ្ឋាន គ្រប់ទំនាក់ទំនងផលប្រយោជន៍ឯកជន ប្រសិនបើមិនផ្ទុយពីបញ្ញត្តិដែលអនុវត្តដោយបង្ខំ និងទំនៀមទំលាប់ល្អរបស់សង្គមទេ តុលាការត្រូវគោរពលើគោលការណ៍នៃការសម្រេចចិត្តរបស់គូភាគី។

**២.២.១.១. ការចរចា**

ការចរចា ជាវិធីសាស្ត្រដ៏សាមញ្ញមួយក្នុងការដោះស្រាយវិវាទ រវាងភាគី និងភាគី ដោយពុំចាំបាច់មានការចូលជួយ អន្តរាគមន៍ ឬសម្របសម្រួលពីតតិយជនណាមួយឡើយ ដែលគូភាគីអាចធ្វើការពិភាក្សា ឬព្រមព្រៀងគ្នា ដើម្បីទទួលបានដំណោះស្រាយសមស្របណាមួយដែលភាគីសងខាងអាចទទួលយកបាន។ ការចរចានឹងនាំឲ្យគូរភាគីមានលទ្ធភាពបង្ហាញនូវឆន្ទៈពិតប្រាកដរបស់ខ្លួន លើកឡើងនូវតម្រូវការដែលចាំបាច់បានដោយគ្មានការលាក់លៀម និងអាចធានាបាននូវប្រសិទ្ធភាពនៃការសម្រេចចិត្តដែលកើតចេញពីឆន្ទៈពិតរបស់ពួកគេ។

ការអនុវត្តនូវការចរចាដើម្បីដោះស្រាយបញ្ហាគឺជាជម្រើសមួយដែលមានភាពងាយស្រួល ឆាប់រហ័ស និងរក្សាបាននូវទំនាក់ទំនងល្អរវាងគ្នា នឹងគ្នា។ ឧទាហរណ៍ថា ក និង ខ បានរៀបការជាមួយគ្នាតាំងពីឆ្នាំ ២០១៤ ហើយអ្នកទាំងពីមានកូនស្រីម្នាក់ជាចំណងដៃ។ ប៉ុន្តែដោយសារតែចំណងអាពាហ៍ពិពាហ៍មួយនេះមិនអាចបន្តទៅមុខទៀតបាន អ្នកទាំងពីរបានសម្រេចចិត្តលែងលះគ្នា។ ក្រោយពេលលែងលះគ្នា អ្នកទាំងពីរបានយល់ព្រមគ្នាលើការចរចា អំពីអ្នកដែលមានកាតព្វកិច្ច ផ្តល់ការផ្គត់ផ្គង់ដល់កូន។ ក សម្រេចយល់ព្រម ប្រគល់កូនស្រីឱ្យ ខ ដែលត្រូវជាម្តាយរបស់កូនជាអ្នកមានសិទ្ធិមើលថែទាំ ហើយខ្លួនជាអ្នកដែលត្រូវផ្គត់ផ្គង់នូវរបបអាហារកាតព្វកិច្ចដល់កូន ដោយយល់ព្រមផ្តល់នូវ ៤០%នៃប្រាក់ខែដែលខ្លួនមានតាមស្ថានភាពជាក់ស្តែង ឱ្យទៅកូន ជារៀងរាល់ ៣ខែម្តង រហូតដល់កូនស្រីមានវ័យ ១៨ឆ្នាំ (គ្រប់នីតិភាព) តាមសំណើរបស់ ខ។

ការចរចាសុំអាហារកាតព្វកិច្ច ក៏អាចធ្វើឡើងដែរ តាមរយៈទំនាក់ទំនងញាតិ ហើយក៏មិនមែនជាកាតព្វកិច្ចដាច់ខាតឡើយ ។ យ៉ាងណាមិញជា ឧទាហរណ៍ទី២ ក និង ខ គឺជា បងប្អូនបង្កើតជាមួយគ្នា អ្នកទាំងពីរមានគ្រួសាររៀងៗខ្លួន ប៉ុន្តែ គ្រួសាររបស់ ខ មានជីវភាពលំបាក។ ខ បានសុំការជួយជ្រោមជ្រែងពី ក ជាបងដែលមានជីវភាពធូរធារជាង ឱ្យជួយផ្គត់ផ្គង់ ដោយអ្នកទាំងពីរបានព្រមព្រៀងគ្នាថា ក នឹងយល់ព្រមជួយផ្គត់ផ្គង់ស្បៀង ជាស្រូវអង្ករដល់គ្រួសារ ខ ដែលជាប្អូន ជារៀងរាល់ ២ខែម្តង និងថវិកា មួយចំនួនតាមលទ្ធភាពជាក់ស្តែង ក្នុងរយៈពេល ២ ឆ្នាំ ដើម្បីឱ្យ ខ ដែលជាប្អូនមានលទ្ធភាពអាចផ្គត់ផ្គង់ជីវភាពគ្រួសារដោយខ្លួនឯងបាន។

ក្រៅពីកិច្ចព្រមព្រៀងលើការផ្គត់ផ្គង់អាហារកាតព្វកិច្ចចំពោះកូន និងចំពោះញាតិ ក៏នៅមានការផ្គត់ផ្គង់អាហារកាតព្វកិច្ចផងដែរចំពោះអតីតសហព័ទ្ធ។ ការផ្តល់ឲ្យនេះអាចធ្វើឡើង ប្រសិនបើការលែងលះនោះ ធ្វើឡើងដោយសារមូលហេតុណាមួយដែលធ្វើឲ្យប៉ះពាល់ដល់ការរស់នៅរបស់ភាគីម្ខាងទៀត នោះភាគីដែលជាអ្នកសុំលែងត្រូវមានតួនាទីផ្គត់ផ្គង់នូវថៃទាំការរស់នៅ ដល់ភាគីម្ខាងទៀត ក្នុងអំឡុងពេលកំណត់ណាមួយ តាមការសុំ ឬចរចារបស់ភាគី។ ឧបមាថា លោក ក បានសុំលែងលះលោកស្រី ខ ស្របពេលលោកស្រី ខ កំពុងតែមានជម្ងឺ។ ខ យល់ព្រមលែងលះតាមការសុំរបស់ ក ប៉ុន្តែ ដោយសារតែ ខ មានជម្ងឺជាប់ខ្លួន ពុំអាចមានលទ្ធភាពប្រកបរបរចិញ្ចឹមខ្លួនឯងដូចពីមុនបាន ទើប ខ បានសុំឲ្យ ក ជួយផ្គត់ផ្គង់ដល់ការរស់នៅរបស់ខ្លួន ក្នុងរយៈកំណត់មួយ។ អ្នកទាំងពីរ បានព្រមព្រៀងគ្នាថា៖ ក និងផ្តល់ទឹកប្រាក់ចំនួន ៤០០០០០៛ ដល់ ខ ដែលជាអតីតសហព័ទ្ធ រៀងរាល់ ២ខែម្តង នឹងស្របតាមស្ថានភាព សេដ្ឋកិច្ចដែលខ្លួនមានជាក់ស្តែង។ ក និង ខ សម្រេចយល់ព្រមលើការព្រមព្រៀងនេះ នាំឲ្យការអនុវត្តនូវរបបអាហារកាតព្វកិច្ច ក៏ចាប់ចាប់ផ្តើមកើតមានឡើង បន្ទាប់កិច្ចចរចាបានសម្រេច ហើយគ្មានការតវ៉ាជំទាស់ពីភាគីសងខាង។

### ២.២.១.២. សន្ធានកម្ម

សន្ធានកម្ម សំដៅលើសកម្មភាពដែលមានវត្តមាននៃភាគីទីបី ឬតតិយជន (ហៅថាសន្ធានការី) ដែលចូលខ្លួនមកជួយសម្របសម្រួលដល់ភាគីដែលមានជម្លោះ ដើម្បីឈានទៅដល់ ការបង្កើតនូវកិច្ចព្រមព្រៀងដ៏សមស្របណាមួយឡើង។ សន្ធានការី គឺត្រូវតែជាមនុស្សដែលមានសតិ បញ្ញា ស្មារតី ចំណេះជំនាញ និងវិជ្ជាជីវៈពាក់ពន្ធ័នឹងវិស័យច្បាប់ ដែលអាចជួយពន្យល់ និងបកស្រាយ នូវចម្ងល់ផ្សេងៗរបស់ភាគីបាន។ ប៉ុន្តែទោះជាយ៉ាងនេះក្តី សន្ធានការីមិនមានសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចអ្វីឡើយ។ សន្ធានការី គឺគ្រាន់តែជាអ្នកដែលស្តាប់ការពិភាក្សារវាងគូភាគី និងព្យាយាមសម្រុះសម្រួលគូភាគីតែប៉ុណ្ណោះ តែសន្ធានការី ក៏អាចបង្កើតយន្តការដាក់លាក់ណាមួយ ដែលស្របនិងគោលបំណងរបស់ភាគី ក្នុងការដោះស្រាយបញ្ហារបស់ភាគី។

ប្រសិនភាគីព្រមទទួលយក និងសម្រេចតាមកិច្ចព្រមព្រៀង ត្រឹមតែការជួយសម្រុះសម្រួលពី សន្ធានការី នោះបានសេចក្តីថាសន្ធានកម្មបានសម្រេច នាំឲ្យកិច្ចចរចាត្រូវបានបញ្ចប់។ ប៉ុន្តែប្រសិនបើ ការចរចា ត្រូវបានបរាជ័យនោះ ភាគីទាំងសងខាង អាចបន្តទៅរកដំណោះស្រាយសមស្របមួយតាមផ្លូវច្បាប់។

**២.២.២. ការទាមទារសិទ្ធិក្នុងការទទួលបានអាហារកាតព្វកិច្ច**

ការបើកឱ្យមានការទាមទារ លើការអនុវត្តនូវរបបអាហារកាតព្វកិច្ច គឺដើម្បីធានាបាននូវការកំណត់ជាដាច់ខាតតាមអំណាចច្បាប់លើករណីយកិច្ចផ្គត់ផ្គង់ និងការថែទាំសំដៅដល់ការរស់នៅដល់ភាគីដែលទាមទារ ឬតតិយជនដែលមានផលប្រយោជន៍។ អាហារកាតព្វកិច្ច ជាកិច្ចដែលត្រូវបំពេញតាមច្បាប់ ឬតាមសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឲ្យបុគ្គលម្នាក់ ឬច្រើននាក់ ផ្តល់នូវប្រាក់កាស ឬទ្រព្យដទៃទៀតដើម្បីជាការទ្រទ្រង់ដល់ការរស់នៅរបស់បុគ្គលផ្សេងទៀត ដែលមានទំនាក់ទងញាតិនឹងគ្នា។

ការដាក់ពាក្យសុំ ឬ ប្តឹងទាមទារអាចធ្វើបានឡើងផងដែរ ប្រសិនជនមានករណីយកិច្ចមានច្រើននាក់ ហើយពួកគេមិនអាចព្រមព្រៀងលើការកំណត់ជនដែលត្រូវផ្គត់ផ្គង់អាហាកាតព្វកិច្ចបាន ពួកគេអាចដាក់ពាក្យសុំទៅតុលាការ ដើម្បីទាមទារការកំណត់រកជនណាម្នាក់ ដែលត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច[29] ។

**២.២.២.១. បរាជ័យក្នុងការពិភាក្សា**

ភាពបរាជ័យក្នុងការពិភាក្សា សំដៅលើភាពមិនចុះសម្រុងគ្នាក្នុងការចចារ ដោយភាគីនីមួយៗមិនអាចរកចំណុចស្របគ្នាបាន មិនថាចចារដោយខ្លួនឯង ឬ មានការជួយសម្រុះសម្រួលពីតតិយជនក៏ដោយ ក៏នៅតែមិនអាចស្វែងរកដំណោះស្រាយដែលសមស្របមួយ។

ចំពោះការដាក់ពាក្យសុំឲ្យតុលាការ ជួយអន្តរាគមន៍ក្នុងការរកដំណោះស្រាយលើការកំណត់កាតព្វកិច្ចលើជនណាម្នាក់ ឬកំណត់ពីទំហំនៃលទ្ធភាពដែលអាចផ្គត់ផ្គង់អាចត្រូវបានធ្វើឡើងគ្រប់ករណី គ្រប់ទំនាក់ទំនងនៃញាតិ ឲ្យតែមានការសុំទាមទារ មិនថាជាប្រភេទអាហារកាតព្វកិច្ចចំពោះកូនជាអនីតិជន, ចំពោះសហព័ទ្ធ, ចំពោះឪពុកម្តាយដែលចាស់ជរា ឬអាហារកាតព្វកិច្ចក្នុងទំនាក់ទំនងញាតិដទៃទៀត។

**២.២.២.២. ការមិនព្រមទទួលសំណើ**

ការមិនព្រមទទួលសំណើសំដៅដល់ការបដិសេដ ឬ ច្រានចោលនូវការស្នើសុំរបស់អ្នកដែលមានសិទ្ធិក្នុងការទាមទារ ពីសំណាក់អ្នកដែលមានករណីយកិច្ចក្នុងការផ្គត់ផ្គង់ដោយមិនសមហេតុផលដែលធ្វើឲ្យមានការខូចប្រយោជន៍តាមផ្លូវច្បាប់របស់អ្នកមានសិទ្ធិ។ អ្នកដែលមានសិទ្ធិក្នុងការទាមទារអាចលើកយកការបដិសេធរបស់អ្នកដែលមានករណីយកិច្ចនេះជាមូលដ្ឋានក្នុងការដាក់ពាក្យស្នើសុំទៅតុលាការដើម្បីឲ្យតុលាការពិនិត្យ និង

[29] ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនបណ្តឹង, លេខ នស/រកម/០៧០១/០១៣, ១០ កក្កដា ២០១០, មាត្រា៣

សម្រេចដល់ខ្លួនបាន។ ការបដិសេធចោលរាល់ការសុំផ្សេងៗ ដោយមិនយកមកពិចារណាសិនសោះឡើយ មិនថាជាការសុំចចារ ឬសុំឱ្យមានការជួយសម្រុះសម្រួលពីសន្ធានការីក៏ដោយ។ សេចក្តីសម្រេចរបស់តុលាការមានអំណាចចាប់បង្ខំ ដែលជាហេតុនាំឲ្យភាគីម្ខាងទៀតត្រូវតែព្រមអនុវត្តនូវកាតព្វកិច្ចជាអ្នកផ្គត់ផ្គង់ជាដាច់ខាត។ ចំពោះទម្រង់បែបបទនៃពាក្យសុំទាមទារអាហារកាតព្វកិច្ច ដូចមានក្នុងឯកសារភ្ជាប់ក្នុងឧបសម្ព័ន្ធ។

ការមិនទទួលសំណើ អាចត្រូវបានកើតឡើងដោយការមិនដឹងពីករណីយកិច្ចរបស់ខ្លួនក្នុងការអនុវត្តសិទ្ធិរបស់អ្នកដែលមានករណីយកិច្ចក្នុងការផ្គត់ផ្គង់ ដែលធ្វើឲ្យពួកគេមានការមិនយល់ស្របក្នុងការទាមទារចង់បាននូវការជួយឧបត្ថម្ភរបស់អ្នកដែលមានសិទ្ធិ និងអាចកើតឡើងដោយការមិនទទួលយកសំណើដោយទុច្ចរិតដើម្បីគេចវេសមិនអនុវត្តដោយមិនមានហេតុផលច្បាស់លាស់ ហើយការដែលមិនបានយល់ដឹងអំពីច្បាប់ក៏ជាមូលហេតុមួយដែលនាំឲ្យជនដែលមានករណីយកិច្ចក្នុងការផ្គត់ផ្គង់អាហារកាតព្វកិច្ចមិនខ្វាយខ្វល់ពីសំណើផងដែរ។

# ជំពូកទី៣

# វត្តមាននៃអាហារកាតព្វកិច្ច

វត្តមានរបបអាហារកាតព្វកិច្ចនៅក្នុងសង្គម គឺជាការលើកកម្ពស់សមភាពសង្គម តុល្យភាពក្នុងការរស់នៅដើម្បីធានាបានការរស់នៅសមរម្យ និងបង្កើនភាពជិតស្និតបន្ថែមទៀតរវាងបុគ្គលដែលមានទំនាក់ទំនងញាតិនឹងគ្នា។ ការផ្គត់ផ្គង់អាហារកាតព្វកិច្ចឯកជន បានចូលរួមចំណែកយ៉ាងច្រើនដល់ការកាត់បន្ថយចំណាយរបស់រដ្ឋក្នុងសង្គម ក៏ប៉ុន្តែវត្តមាននៃរបបអាហារកាតព្វកិច្ច ក៏ផ្តល់នូវផលប៉ះពាល់មួយចំនួនផងដែរ ជាពិសេសចំពោះភាគីដែលមានករណីយកិច្ចក្នុងការផ្គត់ផ្គង់។

## ៣.១. សារប្រយោជន៍ និង ផលអវិជ្ជមាន

### ៣.១.១. ផលវិជ្ជមាននៃអាហារកាតព្វកិច្ច

អាហារកាតព្វកិច្ចគឺជារបបមួយជួយទំនុកបម្រុងផ្នែកសេដ្ឋកិច្ចដល់បុគ្គលដែលមានទំនាក់ទំនងញាតិនឹងគ្នា ដែលបង្ហាញឲ្យឃើញថា ជាកិច្ចដែលជួយសម្រួលដល់ការលំបាករបស់បុគ្គលមួយចំនួនដែលអលទ្ធភាពក្នុងការទ្រទ្រង់ជីវភាពដោយខ្លួនឯងបាន។ អត្ថប្រយោជន៍នៃវត្តមានរបបគតិយុត្ត បង្ហាញពីឥទ្ធិពលដល់ដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចសង្គម ដែលសំដៅដល់ការជួយសម្រាលនូវបន្ទុករដ្ឋ ហើយបានផ្សាភ្ជាប់នូវផលប្រយោជន៍ឯកជនដែលធានាដល់សមភាពក្នុងការរស់នៅ។

#### ៣.១.១.១ ការសម្រាលបន្ទុករដ្ឋ

រដ្ឋ គឺជាអាណាព្យាលរបស់ប្រជាជនគ្រប់រូប ហើយការលំបាករបស់ប្រជាជនគឺជាបន្ទុករបស់រដ្ឋដែលត្រូវដោះស្រាយក្នុងនាមជាអ្នកគ្រប់គ្រងរដ្ឋ ដែលមានកាតព្វកិច្ចមើលថែរក្សា ជួយទំនុកបម្រុង បណ្តុះបណ្តាល និងបង្កើតឱកាសការងារដល់ប្រជាជនរបស់ខ្លួន។ វត្តមាននៃរបបអាហារកាតព្វកិច្ចនឹងរួមចំណែកជួយសម្រាលនូវបន្ទុក តាមរយៈការកាត់បន្ថយនូវការផ្គត់ផ្គង់របស់រដ្ឋដោយការជំនួសមកវិញនូវការជួយជ្រោមជ្រែងពីជនដែលមានទំនាក់ទំនងញាតិនឹងគ្នា ឬអាចនិយាយម្យ៉ាងទៀតបានថា ជាការផ្ទេរនូវការទទួលខុសត្រូវមួយចំនួនដល់សាច់ញាតិ ដើម្បីអនុវត្តនូវករណីយកិច្ចដែលត្រូវទទួលស្គាល់តាមច្បាប់។ ការអនុវត្តអាហារកាតព្វកិច្ចបានពេញលេញ នឹងនាំឲ្យមានភាពល្អប្រសើរទាំងទំនាក់ទំនងឯកជន និងមួយចំណែកទៀតជាការដោះស្រាយនូវការចំណាយថវិការបស់រដ្ឋក្នុងការផ្គត់ផ្គង់បុគ្គលដែលមានសេដ្ឋកិច្ចទន់ខ្សោយមួយផ្នែកផងដែរ។

#### ៣.១.១.២ សមភាពក្នុងការរស់នៅ

វត្តមាននៃរបបអាហារកាតព្វកិច្ច បានស្តែងឱ្យឃើញច្បាស់អំពីសមភាពក្នុងការរស់នៅក្នុងសង្គម ជាពិសេសបង្កើននូវភាពជិតស្និតរវាងគ្នា និងគ្នា ក្នុងទំនាក់ទំនងញាតិ ឱ្យមានភាពស្និតរមួតចំពោះគ្នាទៀតផង។ ការជួយផ្គត់ផ្គង់ ធ្វើឡើងក្នុងសកម្មភាពមួយដើម្បីលើកស្ទួយឲ្យមានតុល្យភាពក្នុងការរស់នៅ ក្នុងទម្រង់មួយ

ដែលទទួលបានការគាំពារផ្នែកចំណីអាហារ ការស្នាក់នៅសមរម្យ និងការថែទាំផ្នែកសុខុមាលភាព ដើម្បីជាការធានាដល់ភាពសមាមាត្រក្នុងការរស់នៅក្នុងសង្គម ។

### ៣.២. ផលអវិជ្ជមាន

មានបញ្ហាជាច្រើនត្រូវបានកើតឡើងកំឡុងពេលអនុវត្តបបអាហារកាតព្វកិច្ចដោយហេតុថា រយៈពេលនៃការអនុវត្តអាចមានរយៈពេលវែងឬខ្លី ធ្វើឲ្យស្ថានភាពមានការប្រែប្រួលទាក់ទងនឹងសេដ្ឋកិច្ចក្នុងការផ្គត់ផ្គង់ដែលអាចកើតឡើងលើជនដែលមានករណីយក្នុងការផ្គត់ផ្គង់ឬក៏កើតឡើងចំពោះជនដែលមានសិទ្ធិទទួល។

#### ៣.២.១. ការកើនឡើងនូវបន្ទុក

បន្ទុកនឹងមានការកើនឡើងសម្រាប់អ្នកដែលមានករណីយកិច្ចក្នុងការផ្គត់ផ្គង់អាហារកាតព្វកិច្ច ដោយហេតុថាស្ថានភាពចាំបាច់ណាមួយនឹងកើតមានឡើងដែលតម្រូវឲ្យអ្នកដែលមានសិទ្ធិទាមទារធ្វើការបន្ថែមបន្ទុកដល់អ្នកដែលមានកាតព្វកិច្ចក្នុងការផ្គត់ផ្គង់។ ស្ថានភាពខ្លះ ក្នុងអំឡុងពេលផ្គត់ផ្គង់អាហារកាតព្វកិច្ច ជនដែលមានសិទ្ធ បានរៀបអាពាហ៍ពិពាហ៍នៅតែមិនអាចទ្រទ្រង់ជីវភាពខ្លួនឯងបាន ដោយរួមទាំងសហព័ទ្ធរបស់ខ្លួនផងជាបញ្ហាថា តើជនដែលសិទ្ធិទាមទារ នៅតែអាចទាមទារអាហារកាតព្វកិច្ចទៀតដែរឬទេ?

ច្បាប់មិនបានកំណត់ពីលក្ខខណ្ឌនៃលុបចោលអាហាកាតព្វកិច្ចដោយអាពាហ៍ពិពាហ៍របស់អ្នកដែលមានសិទ្ធិទាមទារអាហារកាតព្វកិច្ចឡើយ ដោយគ្រាន់តែរំពឹងទុកថា ក្រោយពីអ្នកដែលមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ហើយ បុគ្គលនោះនឹងអាចផ្គង់ផ្គត់ជីវភាពប្រចាំថ្ងៃរបស់ខ្លួនឯងបាន។ បើទោះបីជា ជនដែលមានសិទ្ធិបានរៀបអាពាហ៍ពិពាហ៍ហើយក៏ដោយ ប្រសិនបើគាត់នៅតែបន្តអលទ្ធភាពដោយហេតុផលដែលអាចទទួលយកបានណាមួយ គាត់នៅតែអាចទាមទារអាហារកាតព្វកិច្ចពីជនដែលមានករណីយកិច្ចផ្គត់ផ្គង់បានដដែល។[30]

ជនដែលមានករណីយកិច្ចទទួលបន្ទុករ៉ាប់រងនឹងមានការកើនឡើងដែលអាចធ្វើមានការប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ បើទោះបីជាការទាមទារខាងលើអាចអនុវត្តបានពិតមែន មិនមែនមានន័យថាគាត់ត្រូវតែអនុវត្តបានទាំងស្រុងទេ ការបន្តការផ្គត់ផ្គង់ក្នុងលក្ខណៈនៅតែអាចត្រូវធ្វើទៅបាន ដោយធ្វើការពិចារណាលើតម្រូវការចាំបាច់ (ក្រោយពីបំពេញតម្រូវការគ្រួសាររបស់ជនដែលមានករណីយកិច្ចរួចហើយ) ស្ថានភាពគ្រួសារ លទ្ធភាពទ្រព្យធន របស់ជនដែលមានករណីយកិច្ចផ្គត់ផ្គង់ថា តើក្រោយពីការចំណាយសម្រាប់តម្រូវការចាំបាច់ក្នុងគ្រួសាររបស់គាត់ហើយ គាត់នៅសល់ប្រាក់ប៉ុន្មាន? ប្រសិនបើ ក្រោយពីចំណាយសម្រាប់គ្រួសារហើយ ប្រាក់ដែលនៅសល់ពីការចំណាយអាចក្លាយជាមូលដ្ឋាននៃការលើកយកមកពិចារណារបស់តុលាការថា តើអាចត្រូវផ្តល់ជូនជនដែលមានសិទ្ធិទាមទារប៉ុន្មាន។

[30] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១១៤០ ។

### ៣.២. ការជួបប្រទះបញ្ហាក្នុងការអនុវត្ត

ការអនុវត្តនៅរបបអាហារកាតព្វកិច្ចក៏ប្រទះនឹងបញ្ហាប្រឈម ដែលផ្តល់មកវិញនូវផលវិបាកមួយ ចំនួន។ បញ្ហាប្រឈមគឺជាហេតុនាំឲ្យមានភាពចម្រុងចម្រាស់ក្នុងការវិភាគវែកញែករកដំណោះតាមទំនាក់ទំនងហេតុ និង ផល ដែលមានឥទ្ធិពលយ៉ាងខ្លាំងក្លា ដែលនាំឲ្យខូចប្រយោជន៍ក្នុងការអនុវត្តអាហារកាតព្វកិច្ច ជាពិសេសភាគី ដែលជាជនមានសិទ្ធិក្នុងការទទួលបានអាហារកាតព្វកិច្ច។

#### ៣.២.១. ការបង់ផ្តាច់

ច្បាប់ខ្មែរពុំបានកំណត់ពីនិយមន័យ នៃការបង់ផ្តាច់អាហារកាតព្វកិច្ចនៅឡើយទេ តែជាក់ស្តែងនៅក្នុងការ អនុវត្ត ប្រជាជននៅភាគច្រើនបានយល់ពីពាក្យ "ផ្តាច់" ដោយ ពាក្យ "ផ្តាច់" មានន័យថា ធ្វើឲ្យដាច់។[31] បើស្វែង យល់អត្ថន័យតាមអក្សរសាស្ត្រខ្មែរ ការធ្វើឲ្យដាច់ គឺសំដៅដល់ការកាត់ផ្តាច់ចេញនូវសកម្មភាព ឬ ទំនាក់ទំនង ណាមួយ។ តាមន័យនីតិសាស្ត្រ ការបង់ផ្តាច់អាហារកាតព្វកិច្ច សំដៅដល់ការបង់នូវកញ្ចប់ទឹកប្រាក់ ឬ សម្ភារៈក្នុងការផ្គត់ផ្គង់តម្រូវការដល់ជនដែលមានសិទ្ធិទាមទារ ត្រឹមការកំណត់មួយដើម្បីបញ្ចប់នូវកាតព្វកិច្ច ដោយការបង់តែមួយដងគត់។ ដោយសារ ការបង់ផ្តាច់ត្រូវបង់តែម្តងដើម្បីបញ្ចប់កាតព្វកិច្ចនឹងគ្នា នាំឲ្យអ្នកដែល មានសិទ្ធិមិនអាចទាមទារនៅពេលក្រោយបាន។

ជាទូទៅការបង់ផ្តាច់ ត្រូវបានមើលឃើញថាអាចកើតឡើងស្ទើរតែគ្រប់ទំនាក់ទំនងដែលមានចែងក្នុងច្បាប់ មិនថា ក្នុងទំនាក់ទំនងនៃ ញាតិ សហព័ទ្ធ និងកូនជាអនីតិជន ដែលការអនុវត្តការបង់ផ្តាច់ក៏ផ្តល់មកវិញនូវផល វិបាកផងដែរ ចំពោះគូភាគី និងជនដែលទទួលបានប្រយោជន៍។

##### ៣.២.១.១. ការបង់ផ្តាច់ក្នុងចំណោមញាតិ

កាតព្វកិច្ចនៃការផ្គត់ផ្គង់នឹងត្រូវបានកើតឡើងក្រោយមានការយល់ព្រមរវាងគូភាគីទាំងសងខាង ឬ ក្រោយពីការសម្រេចរបស់តុលាការដើម្បីកំណត់ពីទំហំនៃការផ្គត់ផ្គង់ដល់ជនមានករណីយកិច្ច។ ទំហំនៃការផ្គត់ ផ្គង់អាចត្រូវបានបង់តាមការស្នើសុំ ឬតាមការសម្របសម្រួលរបស់តុលាការ ក្រោយពីពិនិត្យលើស្ថានភាពរបស់ ភាគី។ ការបង់នូវអាហារកាតព្វកិច្ចដែលស្ថិតក្នុងទំនាក់ទំនងញាតិ គឺជាការកំណត់ដើម្បីធានានូវស្ថិរភាពនៃ ជីវភាពកម្រិតអប្បរមារបស់ជនដែលមានសិទ្ធិទទួលអាហារកាតព្វកិច្ចក្នុងការរស់នៅក្នុងសង្គមដែលអាចផ្តល់ លទ្ធភាពក្នុងការរស់នៅសមរម្យមួយ។

[31] វចនានុក្រម សម្តេចសង្ឃរាជ ជួន ណាត បានឲ្យនិយមន័យថា ពាក្យ "ផ្តាច់" (កិរិយាស័ព្ទ) ធ្វើឲ្យដាច់ (បុ. សរ. ផ្តេច)។ ល្អផ្តាច់ ល្អ ដាច់គេ។ ខូចផ្តាច់ ខូចជាងគេ។ ផ្តាច់ផ្តិល ឬ ផ្តិលផ្តាច់ ផ្តិលឲ្យដាច់ផុតលែងមានតទៅទៀត។ ផ្តាច់បង់ កាត់បង់; សម្លាប់។ ផ្តាច់ព្រ័ត្រ (ព. ប្រ.) ធ្វើបង្ហើយត្រឹមប៉ុណ្ណោះលែងធ្វើទៅមុខទៀត : លេងផ្តាច់ព្រ័ត្រ, ធ្វើការផ្តាច់ព្រ័ត្រ (ព. ប្រ.)។

ការធ្លាក់ចុះ ឬការបាត់បង់នូវលទ្ធភាពក្នុងការផ្គត់ផ្គង់ជីវភាពរបស់ជនដែលមានសិទ្ធិគឺមានលក្ខណៈបណ្ដោះអាសន្នប៉ុណ្ណោះ ដែលមិនធ្វើឲ្យគាត់បាត់បង់សមត្ថភាព ឬអលទ្ធភាពជាអចិន្ត្រៃយ៍ឡើយ។ អលទ្ធភាព ស្ថិតក្នុងពេលវេលាមួយដែលយើងអាចធ្វើការព្យាករណ៍បានថាស្ថានភាពដើមនឹងវិលត្រឡប់មកវិញក្នុងពេលខាងមុខ ជនដែលមានសិទ្ធិទាមទារ នឹងវិលត្រឡប់ជាធម្មតាវិញដើម្បីធ្វើការផ្គត់ផ្គង់ខ្លួនឯងដោយឯករាជ្យបាន។ ក្នុងថេរវេលាដែលនាំឲ្យជនដែលមានសិទ្ធិទាមទារ អលទ្ធភាពនោះមានរយៈពេលខ្លីដែលអាចព្យាករណ៍បានអំពីការវិលត្រឡប់ទៅរកស្ថានភាពដើមវិញ ប្រសិនបើជនដែលមានករណីយកិច្ចក្នុងការផ្គត់ផ្គង់អាហារកាតព្វកិច្ចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង់នូវប្រាក់ឧបត្ថម្ភដើម្បីធានានូវស្ថិរភាពជីវភាពរបស់ជនដែលមានសិទ្ធិ ភាគច្រើនគឺតែងតែពិចារណាក្នុងការបង់ផ្ដាច់នូវកាតព្វកិច្ចតែម្ដង ព្រោះដើម្បីកុំឲ្យមានភាពស្មុគស្មាញច្រើនក្នុងការអនុវត្ត។ ប៉ុន្តែគូភាគីអាចពិភាក្សា ឬ តុលាការអាចសម្រេចពីការបង់ជាកញ្ចប់ថវិកាដើម្បីសម្រួលនូវស្ថានភាពវិញបាន មិនមែនមានន័យថាការបង់ គឺជាការបង់ដើម្បីផ្ដាច់ទេតែការជាបង់សម្រាប់ផ្គត់ផ្គង់នូវស្ថានភាពនៃការអលទ្ធភាពជាក់លាក់មួយ។

ប្រសិនបើស្ថានភាពដែលនាំឲ្យអ្នកមានសិទ្ធិអលទ្ធភាពក្នុងទ្រទ្រង់ជីវភាពរបស់ខ្លួនមិនអាចធ្វើការព្យាករណ៍ពីការវិញត្រឡប់វិញបាន ឬការបាត់បង់នូវសមត្ថភាពទាំងស្រុងតែម្ដង វាពិតជាពិបាកណាស់ក្នុងការដែលកំណត់ពីកញ្ចប់នៃអាហារកាតព្វកិច្ច ក្នុងការផ្ដល់ជូនជនដែលមានសិទ្ធិសម្រាប់តម្រូវការជាអប្បរមារបស់គាត់ ព្រោះរយៈពេលនៃការផ្គត់ផ្គង់មានលក្ខណៈវែងដែលតម្រូវឲ្យអ្នកមានករណីយកិច្ចធ្វើការផ្គត់ផ្គង់មួយដែលអាចសម្រួលដល់តម្រូវការជាប្រចាំរបស់បុគ្គលដែលមានសិទ្ធិហូតដល់ស្ថានភាពមានការប្រែប្រួល។ ទំនាក់ទំនងញាតិ និងលក្ខខណ្ឌក្នុងក្រមរដ្ឋប្បវេណី បានបញ្ជាក់ថា ប្រសិនបើច្បាប់អនុញ្ញាតិឲ្យអនុវត្តនូវការបង់ផ្ដាច់ នាំឲ្យទំនាក់ទំនងញាតិដែលចងដោយច្បាប់ហាក់ត្រូវបានកាត់ផ្ដាច់ ដែលធ្វើឲ្យបុគ្គលដែលមានសិទ្ធិក្នុងទាមទារមិនអាចអនុវត្តសិទ្ធិទាមទារអាហារកាតព្វលើកក្រោយបានទៀតឡើយ ព្រោះមិនអាចបំពេញតាមលក្ខខណ្ឌនៃទំនាក់ទំនងញាតិ។ ថេរវេលានៃការបង់អាហារកាតព្វកិច្ចមិនត្រូវបានកំណត់ដោយច្បាប់ឡើយ បាន សេចក្ដីថាច្បាប់បានទុកលទ្ធភាពដល់គូភាគីពិចារណាតាមឆន្ទៈរបស់ខ្លួន តែភាគច្រើនគឺអនុវត្តនូវការបង់ជាប្រចាំខែ ហើយនៅពេលដែលស្ថានភាពមានការប្រែប្រួលតុលាការអាចលុបចោលនូវសេចក្ដីសម្រេចវិញបាន។

### ៣.២.១.២ ការបង់ផ្ដាច់ចំពោះអតីតសហព័ន្ធ

នៅកំឡុងពេលដែលភាគីទាំងពីរស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ ប្ដីប្រពន្ធត្រូវមានកាតព្វកិច្ចស្មើៗគ្នាក្នុងការផ្គត់ផ្គង់សេដ្ឋកិច្ចគ្រួសារ និងមានសិទ្ធិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ អាស្រ័យផលនៃទ្រព្យទាំងឡាយដែលកើតមានក្នុងចំណងអាពាហ៍ពិពាហ៍ដូចៗគ្នា មានន័យថា ប្ដីប្រពន្ធ គឺត្រូវមានស្ថានភាពសេដ្ឋកិច្ចដូចគ្នា បើប្ដី/ប្រពន្ធ មានស្ថានភាពទាប មិនអាច ប្ដី/ប្រពន្ធ ម្ខាងទៀតមានស្ថានភាពខ្ពស់ជាងឡើយ។ គោល

បំណងនៃអាពាហ៍ពិពាហ៍គឺសំដៅដល់ករណីយកិច្ចមើលថែរក្សាគ្នា ផ្គត់ផ្គង់ដល់គ្នាទៅវិញទៅមក។ ប៉ុន្តែក្រោយចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ ឲ្យនាំអានុភាពនៃអាពាហ៍ពិពាហ៍ក៏ត្រូវបានបញ្ចប់ដូចគ្នា មានន័យថាគ្មានទំនាក់ទំនងញាតិនឹងគ្នាទៀតឡើយ ហើយក៏គ្មានករណីយកិច្ចក្នុងការផ្គត់ផ្គង់ដល់គ្នាទៀតដែរ។ ផ្ទុយមកវិញចំណងអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់តាមរយៈការលែងលះ ដោយមូលតុនៃការសុំលែងលះ ហើយប្រសិនបើការលែងលះនោះបានធ្វើឲ្យភាគីដែលត្រូវបានគេសុំលែងលះនោះធ្លាក់ខ្លួនក្រីក្រ ហើយមូលហេតុនៃការលែងលះនេះមិនមែនកើតឡើងដោយកំហុសរបស់ខ្លួនទេនោះ នាំឲ្យភាគីដែលសុំលែងត្រូវមានកាតព្វកិច្ចជួយផ្គត់ផ្គង់ដល់ជីវភាពរស់នៅដល់ភាគីម្ខាងទៀត រហូតដល់ភាគីជាអតីតសហព័ទ្ធនោះរៀបអាពាហ៍ពិពាហ៍ថ្មី តាមការសុំ។[32]

ការកំណត់ ការចាត់ចែងពីការផ្គត់ផ្គង់អាហារកាតព្វកិច្ចរមែងធ្វើឡើងក្នុងទម្រង់ផ្សេងៗ។ យ៉ាងណាមិញក្នុងការបង់អាហារកាតព្វកិច្ចចំពោះអតីតសហព័ទ្ធ ក្នុងស្ថានភាពជាក់ស្តែង ទោះបីជាកើតឡើងដោយការព្រមព្រៀង ឬសុំឲ្យមានការសម្រេចពីតុលាការក្តី យើងតែងសង្កេតឃើញថា ភាគីមួយចំនួនបានទាមទារឲ្យភាគីដែលជាប់កាតព្វកិច្ច ធ្វើការផ្គត់ផ្គង់តាមរយៈការបង់ផ្តាច់តែម្តង។

ផ្ទុយទៅវិញក្នុងកាលៈទេសៈមួយដែលភាគីមិនអាចកំណត់ ឬប៉ាន់ស្មានបានថា តើពេលណាទើបភាគីអាចមានលទ្ធភាពអាចផ្គត់ផ្គង់ ឬស្តារស្ថានភាពរស់នៅរបស់ត្រឡប់ទៅភាពដើមវិញបាន ការបង់ផ្តាច់ពុំគួរអាចអនុវត្តទៅបានឡើយ។ ដោយហេតុថា ការបង់ផ្តាច់មានអនុភាពកាត់ផ្តាច់អស់នូវទំនាក់ទំនងទាំងឡាយ ជាពិសេសទំនាក់ទំនងផ្នែកគតិយុត្តិ ដែលជាហេតុនាំឲ្យប៉ះពាល់ដល់ប្រយោជន៍នៃជនដែលមានសិទ្ធិទទួលបានអាហារកាតព្វកិច្ច។ ក្រៅពីការកាត់ផ្តាច់នូវទំនាក់ទំនងញាតិ ការបង់ផ្តាច់ គឺផ្តល់នូវផលវិបាកដល់ជនដែលមានសិទ្ធិ ប្រសិនបើស្ថានភាពរបស់ជននោះមានភាពប្រែប្រួល។ ឧបមាថា ក្រោយពេលលែងលះ ក ក៏សម្រេចចិត្តចរជាមួយ ខ ថានឹងផ្តល់ការផ្គត់ផ្គង់ជាថវិកាឱ្យទៅ ខ ដែលជាអតីតសហព័ទ្ធ ក្នុងចំនួនទឹកប្រាក់ ៥០០០$ ដើម្បីបញ្ចប់ទំនាក់ទំនង និងកាតព្វកិច្ចនេះតែម្តង។ ក្នុងលក្ខខណ្ឌនេះ យើងឃើញថា ស្ថានភាពរបស់ ខ មិនអាចកំណត់បានទេថា តើពេលណាទើប ខ មានលទ្ធភាពវិលត្រឡប់ទៅភាពដើមវិញ។ ទោះបីជាមានការយល់ព្រមពីភាគីម្ខាងទៀតក៏ដោយ ក៏តុលាការមិនអាចយល់ព្រមសម្រេចតាមការទាមទាររបស់ ភាគី ក បានដែរ ពីព្រោះថា ស្ថានភាពរបស់ ខ អាចនឹងប្រែប្រួល បានសេចក្តីថា ការបង់ផ្តាច់ដោយទឹកប្រាក់ ៥០០០$ មិនអាចធានាបាននូវតុល្យភាពក្នុងការរស់នៅរបស់ភាគី ខ បានឡើយ។ ទោះបីជាអានុភាពនៃការបង់ផ្តាច់នាំឲ្យលត់នូវទំនាក់ញាតិក៏ដោយ ប៉ុន្តែការបង់ផ្តាច់ចំពោះការផ្គត់ផ្គង់អាហារកាតព្វកិច្ចអតីតគូសហព័ទ្ធ អាចធ្វើទៅបានក្នុងករណីដែលមានការយល់ព្រមពីភាគីសងខាង អំពីទំហំនៃការបង់ផ្តាច់ ឬ រយៈពេលនៃការផ្គត់ផ្គង់។

[32] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ. ,១៧ កក្កដា ឆ្នាំ ១៩៨៩, មាត្រា៧៦។

ការបង់ផ្តាច់គួរតែធ្វើឡើងទៅបានក្នុងស្ថានមួយដែលអាចប៉ាន់ស្មានដឹងជាមុនថា ភាគីអាចមានលទ្ធភាពវិលត្រឡប់ទៅសភាពដើម ដែលមានលទ្ធភាពគ្រប់គ្រាន់ផ្គត់ផ្គង់ជីវភាពក្នុងការរស់នៅបានដោយខ្លួនឯង ក្នុងកំឡុងនៃរយៈពេលណាមួយ។ ការបង់ផ្តាច់នូវអាហារកាតព្វកិច្ចចំពោះអតីតសហព័ទ្ធគួរតែពិចារណាដើម្បីអនុវត្តទៅបាន មានន័យថាក្រោយពីការលែងលះទំនាក់ទំនងញាតិក៏ត្រូវបានរលត់ក្រោមអនុភាពនៃការលែងលះដូចគ្នា ហើយការបង់ផ្តាច់ក៏មានអនុភាពដើម្បបញ្ចប់នូវទំនាក់ទំនងញាតិ ហេតុនេះវាគួរតែមិនមានផលអវិជ្ជមានឡើយ និងជារឿងសមហេតុផលផងដែរ។

### ៣.២.១.៣ កូនជាអនីតិជន

កូន គឺជាចំណងដៃមួយមានតម្លៃយ៉ាងធំធេង ក្នុងការផ្សារភ្ជាប់ចំណងអាពាហ៍ពិពាហ៍ឲ្យកាន់តែមានសុភមង្គលថែមទៀត។ ក្នុងអំឡុងពេលស្ថិតនៅក្នុងចំណងអាពាហ៍ពិពាហ៍ ឪពុកម្តាយ ជាអ្នកដែលមានតួនាទី និងករណីយកិច្ច ចិញ្ចឹមបីបាច់ថែរក្សាថែរក្សាកូនប្រុសស្រី។[33] មិនតែប៉ុណ្ណោះ ឪពុកម្តាយក៏មានកាតព្វកិច្ចអប់រំកូនឲ្យក្លាយជាពលរដ្ឋល្អក្នុងសង្គម ហើយកូនៗគ្រប់រូបក៏ត្រូវមានករណីយកិច្ចចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតានៅពេលដែលលោកទាំងពីរចាស់ជរាទៅ។[34]

យ៉ាងណាមិញ នៅពេលចំណងអាពាហ៍ពិពាហ៍ ត្រូវបានបញ្ចប់ កូន មិនអាចស្ថិតនៅក្រោមការមើលខុសត្រូវរបស់ឪពុកម្តាយក្នុងទម្រង់ជារូបភាពមនុស្សរួមដំបូលគ្រួសារតែមួយដូចពីមុនទៀតឡើយ។ នៅពេលដែលអាពាហ៍ពិពាហ៍បានបញ្ចប់ អំណាចមេបាត្រូវបានបែងចែង ដោយម្នាក់ទទួលបានអំណាចជាមេបា ថែរក្សាកូនដោយផ្ទាល់ ឯភាគីម្ខាងទៀតជាបុគ្គលដែលមានករណីយកិច្ចជួយផ្គត់ផ្គង់ ទំនុកបម្រុងដល់កូនតាមរយៈការផ្តល់ជាអាហាររូបត្ថម្ភ សម្ភារៈ និងថវិការជាដើម ដើម្បីជាការសម្រួលដល់ការរស់នៅរបស់កូន ដែលគេហៅថា ការផ្គត់ផ្គង់នូវរបបអាហារកាតព្វកិច្ច ដែលអាហារកាតព្វកិច្ចនេះ ជាប្រភេទអាហារកាតព្វកិច្ចដែលបុគ្គលដែលជាប់កាតព្វកិច្ចផ្តល់ទៅឱ្យភាគីមួយទៀតគឺកូនដែលជាអនីតិជន ឬកូនដែលអលទ្ធភាពក្នុងការផ្គត់ផ្គង់ដល់ការរស់នៅដោយខ្លួនឯងបាន។

ការបង់អាហារកាតព្វកិច្ចចំពោះកូន អាចត្រូវបានធ្វើឡើងតាមរយៈការព្រមព្រៀង ឬតាមការសម្រេចពីតុលាការ។ ច្បាប់ពុំបានដាក់កំហិត លើការកំណត់ពីទំហំអាហារកាតព្វកិច្ច ដែលតម្រូវឲ្យបុគ្គលដែលជាប់កាតព្វកិច្ច បង់ក្នុងទំហំប៉ុណ្ណានោះឡើយ។ មួយវិញទៀតសោត ច្បាប់ក៏ពុំបានចែង ឬបញ្ញត្តិ ត្រង់ឃ្លា ឬចំណុចណាមួយនៃច្បាប់អំពីការបង់ផ្តាច់តែម្តង ដើម្បីបញ្ចប់កាតព្វកិច្ចដូចគ្នា ពីព្រោះថា ការបង់ផ្តាច់បែបនេះធ្វើឱ្យប៉ះ

[33] ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ ក្រ. ,១៧ កក្កដា ១៩៨៩, មាត្រា១១៥(១)។

[34] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣, មាត្រា៤៧។

ពាល់ដល់ផលប្រយោជន៍របស់កូន ដែលជាអ្នកមានសិទ្ធិ។ ក្នុងតថភាពជាក់ស្តែង ស្ថានភាពរស់នៅរបស់កូន រហូតដល់គ្រប់នីតិភាព គឺអាចនឹងមានភាពប្រែប្រួលច្រើន ជាហេតុដែលនាំឲ្យមិនអាចប៉ាន់ស្មាននូវតម្រូវចាំបាច់ផ្សេងៗដែលត្រូវផ្គត់ផ្គង់ ដូចជាស្ថានភាពរស់នៅ ការអប់រំ និងតម្រូវការថែទាំសុខុមាលភាព។ល។ លើសពីនេះទៅទៀត ការបង់ផ្តាច់បែបនេះ មិនមែនត្រឹមតែប៉ះពាល់ដល់ប្រយោជន៍របស់កូនតែប៉ុណ្ណោះទេ ថែមទាំងបានកាត់ផ្តាច់នូវទំនាក់ទំនងញាតិទាំងស្រុងរវាងភាពជា ឪពុកនិងកូន ឬ ម្តាយនិងកូនទៀតផង ដែលជាមូលហេតុមួយមិនអាចផ្តល់លទ្ធភាពឱ្យកូនបានបំពេញនូវកាតព្វកិច្ចមើលថែឪពុកម្តាយវិញ នៅពេលដែលឪពុកម្តាយចូលវ័យជរាទៀតផង។

ក្នុងសេចក្តីចម្លងដីកាសម្រេចអំពីការលែងលះ លេខ ០៣៤ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្តាល បានសម្រេចការតាមព្រមព្រៀងលែងលះរបស់ភាគីដោយប្រគល់អំណាចមេបាលើកូនជា អនីតិជន ចំនួន០៣ នាក់ឲ្យទៅដើមចោទដែលជាម្តាយ។ ទុកសិទ្ធិឲ្យចុងចម្លើយដែលជាឪពុកដែលមិនបានទទួលសិទ្ធិអំណាចមេបាលើកូន ទៅសួរសុខទុក្ខប្រាស្រ័យទាក់ទងជាមួយនឹងកូនតាមផ្លូវច្បាប់។ បង្គាប់ឲ្យចុងចម្លើយដែលជាឪពុកបង់អាហារកិច្ចចំនួន ៤០០.០០០ រៀលទៅឲ្យដើមចោទ។ នៅក្នុងដីកាសម្រេចសេចក្តីនេះ បានបង្គាប់ឲ្យចុងចម្លើយដែលត្រូវជាឪពុកបង់អាហារកិច្ចសម្រាប់កូនចំនួន ៤០០.០០០រៀល ដោយមិនបានបញ្ជាក់ពីកាលបរិច្ឆេទ និងថេរវេលានៃការបង់ឡើយ បានសេចក្តីថា ចុងចម្លើយត្រូវធ្វើការបង់តែម្តងប៉ុណ្ណោះ ដោយមិនមានកាតព្វកិច្ចរ៉ាប់រងនូវបន្ទុកសោហ៊ុយចាំបាច់សម្រាប់ការមើលថែកូនបន្តទៅទៀតទេ រូបភាពនេះដូចជាការបង់ផ្តាច់ដើម្បីនូវកាតព្វកិច្ចរបស់ឪពុកចំពោះកូនជាអនីតិជនដែរ។ កូនៗជាអនីតិជននៅអាចបានទទួលនូវផលប្រយោជន៍ពីផ្គត់ផ្គង់ពីសំណាក់ឪពុកម្តាយរបស់ពួកគេរហូតដល់គ្រប់នីតិភាព ហើយការណ៍ដែលតុលាការសម្រេចតាមការព្រមព្រៀងលះលែងរបស់ភាគីបែបនេះ នឹងនាំឲ្យខូចនូវឧត្តមប្រយោជន៍របស់អនីតិជន និង ដូចជាទទួលស្គាល់នូវការបង់ផ្តាច់ដើម្បីរំលត់នូវកាតព្វកិច្ចក្នុងទំនាក់ទំនងញាតិផងដែរ។ សេចក្តីសម្រេចបានបង្គាប់ឲ្យមានការបង់ប្រាក់អាហារកិច្ចសម្រាប់ចិញ្ចឹមកូនតែមួយដងប៉ុណ្ណោះ ដូចច្នេះរាល់បន្ទុកចំណាយសម្រាប់កូនណាពេលខាងមុខទៀតលែងក្លាយជាន្ទុករបស់ភាគីឪពុកទៀតហើយ ហាក់ដូចឪពុកត្រូវបាត់បង់នូវលទ្ធភាពនៃការរួមចំណែកមើលថែ ទំនុកបម្រុងកូន។

សាលក្រមលេខ ២៧ (ទ) ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្តាលវិញ តុលាការបានសម្រេចក្នុងចំណុចទី៣នៃសាលក្រម បង្គាប់ឲ្យចុងចម្លើយដែលជាឪពុកបង់ប្រាក់អាហារកិច្ចចិញ្ចឹមកូនៗចំនួន ២០០.០០០ រៀល ក្នុងមួយខែឲ្យទៅដើមចោទជាម្តាយ រហូតដល់កូនគ្រប់នីតិភាព។ តាមខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ និងសេចក្តីសម្រេចបញ្ចប់របស់តុលាការ បានតម្កល់នូវឧត្តម

ប្រយោជន៍របស់កូនជាអនីតិជនរហូតដល់គ្រប់នីតិភាព មានន័យថា ចុងចម្លើយដែលជាឪពុកត្រូវទទួលរ៉ាប់រងនូវបន្ទុកសោហ៊ុយសម្រាប់ចិញ្ចឹមកូនជារៀងរាល់ខែរហូតគ្រប់នីតិភាព។ ការបន្តផ្ដល់នូវការឧបត្ថម្ភបែបនេះ គឺដូចជាការបន្តនូវទំនាក់ទំនងឪពុកនឹងកូនផងដែរ បើទោះបីជាមានការលែងលះពិតមែន និងអំណាចមេបាត្រូវបានប្រគល់ឲ្យទៅភាគីម្ដាយជាអ្នកគ្រប់គ្រងមែន តែច្បាប់មិនបានកាត់ផ្ដាច់នូវចំណងញាតិភាពរវាងឪពុកនឹងកូនឡើយ ហើយច្បាប់នៅតែបន្តផ្ដល់លទ្ធភាពដល់ឪពុកក្នុងផ្ដល់អាហារកិច្ចចិញ្ចឹមកូនក្នុងនាមជាឪពុកដដែល (ដើម្បីជាអំណះអំណាងកាន់តែលម្អិត និងច្បាស់លាស់ សូមមើលក្នុងឯកសារភ្ជាប់ដូចមានក្នុងឧបសម្ព័ន្ធ)។

ការបង់អាហារកាតព្វកិច្ច គឺជាកត្តាមួយដែលផ្ដល់លទ្ធក្នុងការផ្សារភ្ជាប់នូវទំនាក់ទំនងញាតិ និងមនោសញ្ចេតនារវាងឪពុកកូន ឬម្ដាយកូន ក្រោយពេលគ្រួសារបាក់បែកគ្នា។ ប្រជាជនខ្មែរតែងប្រកាន់ខ្ជាប់នូវការស្រលាញ់រាប់អាន មេត្តាករុណា កត្តញ្ញូវេទី សណ្ដោសប្រណី នេះជាហេតុផលមួយដែលច្បាប់ខ្មែរ មិនបានបញ្ញត្តិឬលើកឡើងអំពីការបង់ផ្ដាច់ក្នុងការអនុវត្តរបបអាហារកាតព្វកិច្ច ។

### ៣.២.២ អនុភាពនៃការមិនអនុវត្តអាហារកាតព្វកិច្ច

ការមិនព្រមអនុវត្តនូវរបបអាហារកាតព្វកិច្ច ក៏ដូចជាការមិនព្រមអនុវត្តការតព្វកិច្ច សំដៅលើសកម្មភាពដែលភាគីណាមួយមិនអនុវត្តនូវកាតព្វកិច្ចដែលកើតឡើងពីកិច្ចសន្យា[35] ឬការព្រមព្រៀង ឬសេចក្ដីសម្រេចណាមួយ។ សកម្មភាពនៃការអនុវត្តកាតព្វកិច្ចមិនបានពេញលេញ ឬអនុវត្តតែមួយផ្នែកណាមួយ ឬការពន្យាពេលក្នុងការអនុវត្តការផ្ដត់ផ្គង់ ដោយមូលហេតុនៃអះអាងដោយភាគីដែលជាប់ករណីយកិច្ចក្នុងការផ្គត់ផ្គង់។

ប្រសិនបើកិច្ចព្រមពៀង ឬសេចក្ដីសម្រេចរបស់តុលាការបានសម្រេចចេញជាផ្លូវការក្នុងការកំណត់អំពីកាតព្វកិច្ចត្រូវបង់អាហារកាតព្វកិច្ចទៅជនណាម្នាក់ ក៏ដូចជាការសេចក្ដីសម្រេចអំពីសិទ្ធិចំពោះជនដែលមានសិទ្ធិ និងទំហំ ក្នុងការទទួលបាននូវការផ្គត់ផ្គង់ពីជនដែលជាប់កាតព្វកិច្ច ភាគីនីមួយៗត្រូវតែអនុវត្តកាតព្វកិច្ចរបស់ខ្លួនជាចាំបាច់។ ផ្ទុយទៅវិញក្នុងករណីដែលភាគីមិនព្រមអនុវត្តតាមការកំណត់ដែលបានកំណត់រួច នឹងនាំមកនូវផលវិបាកផ្សេងៗដល់ភាគីទាំងសងខាងដូចគ្នា ជាពិសេសជនដែលមានសិទ្ធិ ឬតតីយជនដែលមានផលប្រយោជន៍ ដែលផលវិបាកដែលកើតចេញពីអនុភាពនៃការមិនព្រមអនុវត្ត។

#### ៣.២.២.១.អនុភាពចំពោះជនដែលជាប់ករណីយកិច្ច

ក្នុងកំឡុងពេលដែល សេចក្ដីសម្រេច ឬកិច្ចព្រមព្រៀងត្រូវបានត្រូវបានកំណត់រួច នាំឲ្យចំណងកាតព្វកិច្ចក៏ចាប់កើតមានឡើងចាប់ពីពេលនោះមក ដែលធ្វើឲ្យភាគីនីមួយៗ កាន់តែមានទំនាក់ទំនងជាមួយគ្នាដោយភ្ជាប់នូវលក្ខខណ្ឌនៃវត្តមាននៃអាហារកាតព្វកិច្ច។ ប្រសិនបើ ជនដែលមានករណីយកិច្ចមិនព្រមអនុវត្តកាតព្វកិច្ច

[35] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ៣៨៩(១) ។

របស់ខ្លួនដោយបុព្វហេតុនៃហេតុផលណាមួយមិនជាក់លាក់ ភាគីម្ខាងទៀតដែលជាជនមានសិទ្ធិ មានសិទ្ធិប្ដឹងតវ៉ាទៅតុលាការដើម្បីទាមទារសិទ្ធិក្នុងការចាប់បង្ខំឲ្យជនដែលជាប់ករណីយកិច្ចអនុវត្តនូវកាតព្វកិច្ចដោយបង្ខំ។ ក្នុងទំនាក់រវាងការទាមទារឲ្យអនុវត្តកាតព្វកិច្ច និងមធ្យោបាយផ្សេងៗ ក្នុងករណីភាគី មិនអនុវត្តកាតព្វកិច្ច ភាគីម្ខាងទៀតអាចទាមទារឲ្យសងការខូចខាត ជំនួសការទាមទារ ឲ្យអនុវត្តកាតព្វកិច្ចក្នុងទំហំដែលមិនផ្ទុយគ្នា។[36]

មិនថាក្នុងទំនាក់ទំនងញាតិ សហព័ទ្ធ ឬកូន(អនីតិជន)ឡើយ សុទ្ធតែអាចប្រឈមមុខនិងបញ្ហានេះ។ បើភាគីដែលជាប់ករណីកិច្ច មិនអនុវត្តកាតព្វកិច្ចទេ គឺអាចនឹងត្រូវបានភាគីម្ខាងទៀតប្ដឹងផ្ដល់ និងទាមទារសំណងផ្សេងៗ ប្រសិនបើមូលហេតុនៃការមិនព្រមអនុវត្តកាតព្វកិច្ចក្នុងការផ្គត់ផ្គង់ មិនអាចពន្យល់ ឬការអះអាងពីមូលហេតុទាំងនោះមិនសមហេតុផល ពុំអាចឱ្យភាគីម្ខាងទៀតទទួលយកបាន។ឧទាហរណ៍ ក និង ខ គឺជា បងប្អូនបង្កើតជាមួយគ្នា។ អ្នកទាំងពីរមានគ្រួសាររៀងៗខ្លួន ប៉ុន្តែ គ្រួសាររបស់ ខ មានជីវភាពលំបាក។ ដូចច្នេះ ខ បានសុំការជួយជ្រោមជ្រែងពី ក ជាបងដែលមានជីវភាពធូរធារជាង ឱ្យជួយផ្គត់ផ្គង់។ អ្នកទាំងពីរបានព្រមព្រៀងគ្នាថា ក នឹងយល់ព្រមជួយផ្គត់ផ្គង់ស្បៀងជាស្រូវអង្ករដល់គ្រួសារ ខ ដែលជាប្អូន ជារៀងរាល់ ២ខែម្ដង និងថវិកា មួយចំនួនតាមលទ្ធភាពជាក់ស្ដែង ក្នុងរយៈពេល ២ ឆ្នាំ ដើម្បីឱ្យ ខ ដែលជាប្អូនមានលទ្ធភាពអាចផ្គត់ផ្គង់ជីវភាពគ្រួសារដោយខ្លួនឯងបាន។ ខ និង ក បានយល់ស្របគ្នាចំពោះការព្រមព្រៀងនេះ។ ប៉ុន្តែ ក្រោយពេលសម្រេចកិច្ចព្រមព្រៀងគ្នារួច ក ពុំបានអនុវត្តតាមអ្វីដែលបានចរចាគ្នាឡើយ ជាហេតុធ្វើឲ្យ ខ ដែលជាប្អូនកើតទុក្ខមិនសុខចិត្តចំពោះភាពប្រែក្រឡាស់របស់ ក ដែលជាបង ក៏បានសម្រេចចិត្តដាក់ពាក្យប្ដឹង ក ដែលជាបងពីបទ មិនព្រមអនុវត្តកាតព្វកិច្ចតាមកិច្ចសន្យា ឬការព្រមព្រៀងនេះ។

ការដាក់បន្ទុកឲ្យភាគីម្ខាងទៀតអនុវត្តនឹងកើតមានឡើងគ្រប់ពេល ប្រសិនបើភាគីមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួន ការអនុវត្តមិនបានពេញលេញ ឬការអនុវត្តតែមួយជ្រុងឬមួយផ្នែកក៏ដោយ។

ការប្ដឹងទាមទារអាហារកាតព្វកិច្ចរបស់អតីតសហព័ទ្ធ ដើម្បីឲ្យអតីតសហព័ទ្ធម្ខាងទៀត ធ្វើការបង់នូវអាហារកាតព្វកិច្ចដល់ខ្លួន។ ប៉ុន្តែក្នុងក្រមរដ្ឋប្បវេណី កាលណាសហព័ទ្ធបានលែងលះគ្នា ចំណងញាតិភាពក៏ត្រូវបានបញ្ចប់ដែរ ហេតុដូចនេះហើយ ប្រសិនបើតុលាការសម្រេចទទួលបណ្ដឹងប្ដឹងទាមទារអាហារកាតព្វកិច្ច តើតុលាការត្រូវសម្រេចដោយផ្អែកលើច្បាប់សារធាតុអ្វី? "ជាទស្សនាទានៈ អតីតសហព័ទ្ធ អាចដើម្បីប្ដឹងទាមទារឲ្យអតីតសហព័ទ្ធរបស់ខ្លួនធ្វើការបង់នូវអាហារកាតព្វកិច្ចបាន លុះត្រាតែនៅក្នុងសាលក្រមលះលែង ឬសេចក្ដី

[36] ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា៣៩៧។

សម្រេចឲ្យបង់នូវអាហារកិច្ច តុលាការបានតម្រូវឲ្យអតីតសហព័ទ្ធត្រូវធ្វើការបង់អាហារកាតព្វកិច្ចដល់អតីតសហព័ទ្ធ ឬ កូនជាអនីតិជន បច្ឆាញាតិ បុព្វញាតិ ឬដល់ញាតិផ្សេងទៀតរបស់ខ្លួននោះ។[37]

### ៣.២.២.២. អនុភាពចំពោះជនដែលមានសិទ្ធិ

ប្រសិនបើ ការផ្គត់ផ្គង់អាហារកាតព្វកិច្ចត្រូវបានបដិសេដមិនព្រមអនុវត្ត នោះជនដែលមានសិទ្ធិ ឬ ជនដែលមានសេដ្ឋកិច្ចទាប ឬជនដែលខ្វះខាត ឬជនអលទ្ធភាព ក្នុងការទ្រទ្រង់ស្ថានភាពរស់នៅរបស់ខ្លួនដោយខ្លួនឯង នឹងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។

ផលវិបាកចំពោះជនដែលមានសិទ្ធិ ដែលនឹងអាចត្រូវប្រឈម ក្រោមបុព្វហេតុនៃការមិនព្រមផ្គត់ផ្គង់អាហារកាតព្វកិច្ចពីជនដែលជាប់ករណីយកិច្ច ឬ ការបំពេញកាតព្វកិច្ចផ្គត់ផ្គង់មិនពេញលេញ ឬផ្គត់ផ្គង់ត្រឹមពាក់កណ្តាលទី ឬបញ្ឈប់ការផ្គត់ផ្គង់មុនពេលវេលាដែលបានកំណត់នោះ ជាហេតុនាំឲ្យប៉ះពាល់ដល់ផលប្រយោជន៍ភាគីដែលមានសិទ្ធិ។ ផលប៉ះពាល់នេះមិនត្រឹមតែមានឥទ្ធិពលដល់ផលប្រយោជន៍ផ្នែកកាយសម្បទាររបស់ភាគី ដែលពាក់ព័ន្ធដល់ជីវភាពរស់នៅ និងការសិក្សាអប់រំ (ករណីភាគីដែលមានសិទ្ធិគឺជាអនីតិជនដែលចាំបាច់ត្រូវទទួលបានការសិក្សាអប់រំ)ប៉ុណ្ណោះទេ ថែមទាំងអាចជាមូលហេតុមួយក្នុងការផ្លាស់ប្តូរលទ្ធភាពក្នុងការរស់នៅ សំដៅទៅលើការថែទាំផ្នែកសុខុមាលភាព និងស្ថានភាពប្រែប្រួលផ្សេងៗដទៃមួយចំនួនទៀតផងដែរ។ឧបមាថា ក និង ខ ជាបងប្អូននឹងគ្នា។ ក្រោយពេលឪពុកម្តាយលាចាកលោកបាត់ទៅ ខ បានទៅរស់នៅជាមួយ ក ដែលជាបង។ កំឡុងពេលនេះ បើអត់ពីឪពុកម្តាយទៅហើយ ក ត្រូវទទួលបន្ទុករ៉ាប់រងគ្រួសារជំនួសឪពុកម្តាយ ក៏ដូចជាមានតួនាទី ជួយចិញ្ចឹមបីបាច់ថែរក្សា ខ ដែលត្រូវជាប្អូន។ ការមើលថែត្រង់ចំណុចនេះ រាប់បញ្ចូលទាំងការផ្គត់ផ្គង់ផ្នែកចំណីអាហារ ការស្នាក់អាស្រ័យ ការសិក្សាអប់រំ និងការថែទាំផ្នែកសុខុមាលភាពដល់ ខ ទៀតផង។

ករណីទី១ ៖ ក មិនអនុញ្ញាតឱ្យ ខ ដែលជាប្អូនស្នាក់នៅជាមួយខ្លួនតទៅទៀត ហើយបដិសេដចោលនូវករណីយកិច្ចផ្គត់ផ្គង់ការរស់នៅរបស់ ខ គឺបង្ហាញឱ្យឃើញអំពីការមិនព្រមអនុវត្តកាតព្វកិច្ចកិច្ចក្នុងការផ្គត់ផ្គង់ទាំងស្រុង ធ្វើឱ្យភាគី ខ ត្រូវបាត់បង់ប្រយោជន៍ស្របច្បាប់ដែលខ្លួនអាចមានសំដៅលើ លទ្ធភាពក្នុងការរស់នៅប្រចាំថ្ងៃ ដូចជា សិទ្ធិទទួលបានការស្នាក់នៅសមរម្យ សិទ្ធិក្នុងការទទួលបានការសិក្សាអប់រំ និងសិទ្ធិទទួលបានការថែទាំផ្នែកសុខុមាលភាពជាដើម។

[37] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣២៤។

ករណីទី២ ៖ ក យល់ព្រមឱ្យ ខ ស្នាក់អាស្រ័យជាមួយខ្លួន និងយល់ព្រមផ្គត់ផ្គង់ចំណីអាហារ ដើម្បីធានាដល់ការរស់នៅប្រចាំថ្ងៃ ប៉ុន្តែសុំបដិសេដមិនផ្គត់ផ្គង់លើការអប់រំ និងការថែទាំផ្នែកសុខុមាលភាព បង្ហាញអំពីការផ្គត់ផ្គង់តែមួយផ្នែក ឬហៅថាការផ្គត់ផ្គង់មិនបានពេញលេញ ដោយបានបំបាត់នូវតម្រូវការចាំបាច់សំខាន់ៗចំនួនពីរគឺ ការទទួលបានការសិក្សាអប់រំ និងការថែទាំផ្នែកសុខុមាលភាព។

ករណីទី៣ ៖ ក យល់ព្រមផ្គត់ផ្គង់ដល់ ខ ជាប្អូននូវរបស់ជីវព្រឹត្ត ការស្នាក់នៅ ផ្តល់លទ្ធភាពឱ្យ ខ ទទួលបានការអប់រំ និងការថែទាំផ្នែកសុខុមាលភាព ។ ក៏ប៉ុន្តែ ក បានទទួលរ៉ាប់រងអនុវត្តចំពោះកាតព្វកិច្ចជាអាណាព្យាបាលដែលជាប់ករណីយកិច្ច ត្រឹមតែរយៈពេលបីឆ្នាំប៉ុណ្ណោះ។ បានសេចក្តីថា រយៈពេល ៣ឆ្នាំដែល កបានអនុវត្តនេះ គឺបានត្រឹមតែពាក់កណ្តាលនៃការព្រមព្រៀង ឬសេចក្តីតែប៉ុណ្ណោះ។ បានបង្ហាញឲ្យឃើញអំពីការផ្គត់ផ្គង់ត្រឹមពាក់កណ្តាលទី មានន័យថាបញ្ចប់កាតព្វកិច្ចក្នុងការផ្គត់ផ្គង់មុនពេលកំណត់បានមកដល់ដោយខ្លួនឯងហើយក៏មិនបានបញ្ជាក់ពីហេតុផលឲ្យបានសមរម្យដែរ។ សកម្មភាពនេះ ប៉ះពាល់យ៉ាងខ្លាំងចំពោះប្រយោជន៍របស់ជនដែលមានសិទ្ធិក្នុងការធានាដល់ស្ថានភាពរស់នៅរបស់ជននោះ ជាពិសេសពាក់ព័ន្ធស្ថានភាពនៃការសិក្សាអប់រំ និងលទ្ធភាពក្នុងការទទួលបានសេវាសុខភាព ដូចជនដទៃទៀត។

ទោះបីជនដែលមានសិទ្ធិគឺជា កូន(អនីតិជន) បងប្អូន( អនីតិជន ឬនីតិជន) ញាតិ និងសហព័ទ្ធក្តី ក៏រមែងទទួលរងនូវផលប៉ះពាល់ដូចមានរៀបរាប់ខាងលើដូចគ្នា ដោយជនខ្លះទទួលរងផលប៉ះពាល់នោះទាំងស្រង់ ឬដោយផ្នែកណាមួយក៏ដោយ ក៏ជាចំណែកមួយដែលបានកើតឡើងដោយបុព្វហេតុភាគីមិនអនុវត្តកាតព្វកិច្ចដូចគ្នា។ ក្នុងន័យនេះគឺគ្រាន់តែជាការបង្ហាញពីចំណុចៗដែលតែងកើតមាន ប៉ុន្តែពេលខ្លះជនដែលមានសិទ្ធិមិនបានដឹងថាជាការប៉ះពាល់ចំពោះអ្វីដែលខ្លួនអាចទទួលបានយ៉ាងស្របច្បាប់។

ម្យ៉ាងវិញទៀត មិនថាក្នុងទំនាក់ទំនងញាតិណាមួយក៏ដោយ បើសិនជាជាប់ចំណងកាតព្វកិច្ចក្នុងការផ្គត់ផ្គង់អាហារកាតព្វកិច្ច ហើយមិនព្រមអនុវត្ត ឬអនុវត្តមិនបានពេញលេញ ឬបញ្ចប់កាតព្វកិច្ចក្នុងការអនុវត្តការផ្គត់ផ្គង់មុនពេលកំណត់ដោយខ្លួនឯង សុទ្ធតែផ្តល់ផលប៉ះពាល់ដូចៗគ្នា អាចថា តិចឬច្រើន អាស្រ័យលើស្ថានភាពជាក់ស្តែង។

# សេចក្តីសន្និដ្ឋាន

អាហារកាតព្វកិច្ច ជាមធ្យោបាយមួយដ៏ល្អក្នុងការជួយជ្រោមជ្រែងផ្នែកសេដ្ឋកិច្ចដល់កូន អតីតសហពទ្ធ័ និងញាតិ ដែលអលទ្ធភាពក្នុងការផ្គត់ផ្គង់ការរស់នៅដោយខ្លួនឯង ដើម្បីធានាឲ្យបានថា បុគ្គលនោះអាចរស់នៅបានសមរម្យក្នុងសង្គម ហើយក៏ជាការរួមចំណែកក្នុងការកាត់បន្ថយនូវបន្ទុករបស់រដ្ឋក្នុងការផ្គត់ផ្គង់ដល់ប្រជាពលរដ្ឋដែលជួបបញ្ហាផ្នែកសេដ្ឋកិច្ចក្នុងជីវភាពប្រចាំថ្ងៃ។

ការអនុវត្តអាហារកាតព្វកិច្ចបានបង្ហាញពីផលវិជ្ជមាន និងផលអវិជ្ជមាន ជាពិសេសបញ្ហាសេដ្ឋកិច្ចរបស់ជនដែលមានកាតព្វកិច្ចក្នុងការផ្គង់ផ្គត់អាហារកាតព្វកិច្ច ទទួលបន្ទុកចំណាយដល់ជនបុគ្គលដែលមានសិទ្ធិទទួល ប្រសិនបើបុគ្គលដែលមានកាតព្វកិច្ចក្នុងការផ្គង់ផ្គង់មានជីវភាពខ្វះខាត។ ការអនុវត្តកាតព្វកិច្ចមិនបានពេញលេញរបស់បុគ្គលដែលមានកាតព្វកិច្ចក្នុងការផ្គត់ផ្គង់ ក៏មានជាផលវិបាកមួយចំនួនដល់បុគ្គលមានសិទ្ធិក្នុងការទទួលបានការផ្គត់ផ្គងដែរ ហើយប្រសិនបើបុគ្គលដែលមានកាតព្វកិច្ចក្នុងកាផ្គត់ផ្គង់មិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន នឹងជះឥទ្ធិពលអវិជ្ជមានដល់អ្នកដែលមានសេដ្ឋកិច្ចទន់ខ្សោយ។

# អនុសាសន៍

ច្បាប់កម្ពុជាគួរតែបញ្ជាក់លំអិតឲ្យច្បាស់បន្ថែមទៀតពាក់ព័ន្ធនឹងភាពស្រពេចស្រពិលនៃច្បាប់ ដើម្បីភាពងាយស្រួលក្នុងការអនុវត្ត និងបង្កើននូវប្រសិទ្ធភាពនៃការអនុវត្តច្បាប់ឲ្យកាន់តែប្រសើរទ្វេដង ដោយជៀសវាងនាំឲ្យមានការបកស្រាយផ្សេងៗគ្នានៃអ្នកអនុវត្តច្បាប់។ ជម្រុញឲ្យមានការផ្សព្វផ្សាយដើម្បីលើកកម្ពស់ឲ្យមានការយល់ដឹងកាន់តែទូលាយអំពីអាហារកាតព្វកិច្ច និងកំណត់ពីទណ្ឌកម្ម ឬ បទបញ្ញតិចាប់បង្ខំដល់បុគ្គលដែលមិនអនុវត្តកាតព្វកិច្ច គឺជាការធានាអំពីគុណភាពនៃការយល់ដឹងរបស់ពលរដ្ឋខ្មែរក្នុងវិស័យច្បាប់ក្នុងប្រទេសកម្ពុជា នឹងដើម្បីធានាអំពីប្រសិទ្ធភាពច្បាប់។

# ឯកសារយោង


## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២១ កញ្ញា ១៩៩៣។

ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ១៩២០។

ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។

ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, លេខ នស/រកប/០៥១១/០០៧, ៣១ ឧសភា ២០១១។

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, លេខ ៥៦ក្រ. , ១៧ កក្កដា ១៩៨៩។

ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនបណ្តឹង, លេខ នស/រកម/០៧០១/០១៣, ១០ កក្កដា២០១០។

## សៀវភៅបោះពុម្ពផ្សាយជាខេមរភាសា

ក្រុមការងារនៃគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រម, សេចក្តីពន្យល់អំពីក្រមរដ្ឋប្បវេណីភាគ៣ (ភ្នំពេញ៖ ក្រសួងយុត្តិធម៌ ២០១៧)។

ក្រសួងយុត្តិធម៌៖ ការិយាល័យកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌, សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី, (ភ្នំពេញ៖២០១០)។

## ឯកសាសិក្ខាសាលាជាខេមរភាសា

ក្រុមការងារគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា, សិក្ខាសាលាគណៈមេធាវី (តូច) លើកទី៥, ប្រធានបទ៖ អាហារកាតព្វកិច្ច, ២៥ វិច្ឆិកា ២០១៤។

## ឯកសារជាខេមរភាសាដកស្រង់ពីអ៊ីនធឺណិត

Fresh News, យល់ដឹងផ្នែកច្បាប់៖ អាហារកាតព្វកិច្ចតាមផ្លូវច្បាប់ (ភ្នំពេញ៖ ២០២០) អាចរកបាននៅ http://m.freshnewsasia.com/index.php/en/localnews/162314-2020-06-14-06-42-02.html (ថតចម្លងថ្ងៃទី ១៤ មេសា ២០២០)។

ស្ថានីយទូរទស្សន៍ BTV, កម្មវិធីនាទីច្បាប់៖ អាហារកាតព្វកិច្ច ( ភ្នំពេញ៖ ឆ្នាំ២០១៦) អាចរកមើលបាននៅ https://youtu.be/kS__yLCPW5s (ថតចម្លងថ្ងៃទី ១៤ មេសា។)

## សេចក្តីសម្រេចរបស់តុលាការ

សេចក្តីចម្លងដីកាសម្រេចអំពីការលែងលះរបស់សាលាដំបូងខេត្តកណ្តាល, លេខ០៣៤, ២៩ ឧសភា ២០២០។

សាលក្រមសាលាដំបូងខេត្តកណ្តាល, លេខ ២៧ (ទ), ០៥ ឧសភា ២០២០។

# ឧបសម្ព័ន្ធ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្ដាល
លេខៈ ....០៣៤....

## ដីកាសម្រេចអំពីការលែងលះ

យើង [illegible] ចៅក្រមសាលាដំបូងខេត្តកណ្ដាល ។

បានឃើញ មាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។

បានឃើញ មាត្រា៣ កឋាខណ្ឌទី២ នៃច្បាប់ស្ដីពីនីតិវិធីរឿងក្ដីរដ្ឋប្បវេណីមិនមែនបណ្ដឹង ។

បានឃើញ ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីមិនមែនបណ្ដឹងលេខៈ ០៦១ ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកណ្ដាល មានកម្មវត្ថុៈ ពាក្យសុំចេញដីកាសម្រេចលែងលះ ។

-ដើមចោទឈ្មោះ [illegible] ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិតារាបដូនស ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

-និងចុងចម្លើយឈ្មោះ [illegible] ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិតារាបដូនស ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្ដាល ។

បានឃើញ សំបុត្រអាពាហ៍ពិពាហ៍លេខៈ ៣៨ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៨ សៀវភៅអាពាហ៍ពិពាហ៍លេខៈ ០១/២០០៨ ឆ្នាំ២០០៨ របស់មន្ត្រីអត្រានុកូលដ្ឋានឃុំគគីរ ។

បានឃើញ កិច្ចព្រមព្រៀងលែងលះ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២០ រវាងឈ្មោះ [illegible] និងឈ្មោះ [illegible] ។

### សំអាងហេតុ

១-តាមការសាកសួរភាគី និងពិនិត្យភស្តុតាងឯកសារ ឃើញថាដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ ជាមួយគ្នាតាមប្រពៃណីកាលពីឆ្នាំ២០០៨ និងបាននាំគ្នាទៅចុះសំបុត្រអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំគគីរ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខៈ ៣៨ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៨ សៀវភៅអាពាហ៍ពិពាហ៍លេខៈ ០១/២០០៨ ឆ្នាំ២០០៨ របស់មន្ត្រីអត្រានុកូលដ្ឋានឃុំគគីរ ។

ការរួមរស់កន្លងមក មានការមិនចុះសម្រុងនឹងគ្នា ចេះតែមានរកាំរកូសនឹងគ្នាជាញឹកញាប់រហូតធ្វើឲ្យគូភាគីអស់ចិត្ត អស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាជាប្ដីប្រពន្ធតទៅទៀតបាន ។

២-តុលាការបានសកល្បងធ្វើការផ្សះផ្សារ ប៉ុន្តែគូភាគីបានអះអាងថា អស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយ គ្នាជាប្ដីប្រពន្ធតទៅទៀតបាន ។ គូភាគីបានព្រមព្រៀងដូចតទៅ ៖

-លែងលះដោយការស្ម័គ្រចិត្ត ។

-ប្រគល់កូនៈ

ក-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ ។

ខ-ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២ ។

គ-ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០២ ទៅដើមចោទជាអ្នកគ្រប់គ្រង។

ដោយពិចារណាឃើញថាគូភាគីពិតជាមានបំណងក្នុងការលែងលះពីគ្នាជាការពិតមែនដូច្នេះតុលាការពិចារណាសម្រេចតាមឆន្ទៈរបស់គូភាគី និងដោយផ្អែកតាមមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី ។

ចំពោះកូនតុលាការសម្រេចពីអ្នកមានអំណាចមេបាតាមការពិភាក្សាឯកភាពរបស់គូភាគី យោងមាត្រា ១០៣៧ កឋា ខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ។ ភាគីដែលមិនមានអំណាចមេបាលើកូន មានសិទ្ធិចូលជួបនិងប្រាស្រ័យទាក់ទង ជាមួយកូន និងមានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន (មាត្រា ១០៤០ កឋាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី) ។

តុលាការចេញដីកាសម្រេចអំពីការលែងលះ ដោយផ្អែកតាមមាត្រា ៣ កឋាខណ្ឌទី២ និងមាត្រា ៣៥ នៃច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីមិនមែនបណ្តឹង ។

៣-គូភាគីបានអះអាងថា ទ្រព្យសម្បត្តិរួមមាន ផ្ទះល្វែងទំហំ៥ម៉ែត្រX១៦,៥០ម៉ែត្រ បានឯកភាពទុកឲ្យកូនទាំង០៣ខាងលើ ។ គប្បីតុលាការសម្រេចតាមការព្រមព្រៀង ។

៤-ចំពោះប្រាក់ពន្ធនិងប្រាក់ប្រដាប់ក្តី ត្រូវអនុវត្តតាមមាត្រា២២ នៃច្បាប់ស្តីពីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១-ឲ្យដើមចោទឈ្មោះ [redacted] ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិតារាបដូនស ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល និងចុងចម្លើយឈ្មោះ [redacted] ភេទប្រុស អាយុ៣៤ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិតារាបដូនស ឃុំគគីរ ស្រុកកៀនស្វាយ ខេត្តកណ្តាល លែងលះគ្នាតាមការព្រមព្រៀង ។

២-ប្រគល់សិទ្ធិអំណាចមេបាលើកូន៖

ក-ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ ។

ខ-ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១២ ។

គ-ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០២ ឲ្យទៅដើមចោទឈ្មោះ [redacted] ជាម្តាយ ។

ទុកសិទ្ធិឲ្យចុងចម្លើយឈ្មោះ [redacted] ដែលមិនបានទទួលសិទ្ធិអំណាចមេបាលើកូន ទៅសាកសួរសុខទុក្ខប្រាស្រ័យទាក់ទងជាមួយនឹងកូនច្បាប់ ។

៣-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] បង់អាហារកិច្ចចិញ្ចឹមកូនចំនួន៤០០.០០០ (សែសិបម៉ឺន)រៀលទៅឲ្យដើមចោទឈ្មោះ [redacted] ។

៤-រឹបអូសប្រាក់ពន្ធនិងប្រាក់ប្រដាប់ក្តីតាមច្បាប់ ។

ហត្ថលេខា និងត្រា ស៊ឹម កល្យាណ

ហត្ថលេខា និងត្រា ជួន វណ្ណៈ

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ៨កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ខេត្តកណ្តាល,ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

បានឃើញ

**ចៅក្រម**

**ជួន_វណ្ណះ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកណ្ដាល**
សំណុំរឿងរដ្ឋប្បវេណីលេខ ១០៤២
ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩
សាលក្រមលេខ ២៧ (ទ)
ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០

តាងនាមប្រជារាស្ត្រខ្មែរ
**សាលាដំបូងខេត្តកណ្ដាល**
បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់
នៅថ្ងៃទ២១ ខែមេសា ឆ្នាំ២០២០
ដោយមានសមាសភាព:
-លោក [illegible] ចៅក្រម
-លោក [illegible] ក្រឡាបញ្ជី

-ដើមចោទឈ្មោះ [illegible] ភេទស្រី អាយុ២៩ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅខេត្តកណ្ដាល ។

លោក [illegible] ជាមេធាវីតំណាងដោយអាណត្តិ ។

អ្នកជំនួយការ គ្មាន។

អ្នកបកប្រែភាសា គ្មាន។

-ចុងចម្លើយឈ្មោះ [illegible] ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិព្រែកក្រាញ់ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្ដាល ។

មេធាវីតំណាងដោយអាណត្តិ គ្មាន។

អ្នកជំនួយការ គ្មាន។

អ្នកបកប្រែភាសា គ្មាន។

## អង្គហេតុ និងចំណុចវិវាទ

១.ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ:

ក.លែងលះពីចុងចម្លើយឈ្មោះ [illegible] ។

ខ.មានសិទ្ធិអំណាចមេបាលើកូនចំនួន០២នាក់ ។

គ.ឲ្យចុងចម្លើយផ្ដល់អាហារកិច្ចចិញ្ចឹមកូនទាំង០២នាក់ ចំនួន ២០០.០០០ (ពីរសែន) រៀលក្នុង ០១ខែ ។

ឃ.ទាមទារផ្ទះ១ល្វែងទំហំ ៤,៥ម៉ែត្រ គុណនឹង ៩ម៉ែត្រ ស្ថិតនៅភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្ដាល សម្រាប់ស្នាក់នៅជាមួយកូនៗ ។

ង.ឲ្យចុងចម្លើយជាអ្នកបង់ប្រាក់ប្រដាប់ក្តី ។

**២.ការពន្យល់ត្រួសៗអំពីរឿងក្តី:**

ដើមចោទឈ្មោះ [redacted] និងចុងចម្លើយឈ្មោះ [redacted] បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ និងបានចុះសំបុត្រអាពាហ៍ត្រឹមត្រូវតាមច្បាប់ ។ ក្នុងចំណងអាពាហ៍អាពិពាហ៍ ដើមចោទ និងចុងចម្លើយបង្កើតបានកូនចំនួន ២ (ពីរ) នាក់ ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៣ និងឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៥ និងមានទ្រព្យសម្បត្តិរួមផ្ទះថ្ម ១ ល្វែង ទំហំ ៤.៥ម៉ែត្រ គុណនឹង ៩ម៉ែត្រ សាងសង់អស់ប្រាក់ចំនួន ៣.០០០ (បីពាន់) ដុល្លាអាមេរិក និងមានបំណុលរួមជំពាក់មាសបងស្រីចំនួន ២ (ពីរ) ជីមាស ។ ការរស់នៅជាមួយគ្នា ដើមចោទ និងចុងចម្លើយរស់នៅមិនចុះសម្រុងនឹងគ្នា ដោយសារចុងចម្លើយតែងតែដើរផឹកស៊ីស្រវឹងស្ទើរាល់ថ្ងៃ ហើយពេលចូលផ្ទះតែងតែរករឿងឈ្លោះប្រកែកគ្នា ហើយពេលខ្លះបានប្រើហិង្សាមកលើដើមចោទទៀតផង ។ នៅក្នុងខែមីនា ឆ្នាំ២០១៨ ចុងចម្លើយបានចុះចោលដើមចោទ និងកូនរហូតមកដល់សព្វថ្ងៃនេះ ដោយមិនបានជួយផ្គត់ផ្គង់គ្រួសារនោះទេ ធ្វើឲ្យដើមចោទអស់មនោសញ្ចេតនាជាប្រពន្ធប្តីនឹងគ្នាតទៅទៀត ។

**៣.ការអះអាងរបស់ភាគី:**

ដើមចោទឈ្មោះ [redacted] បានអះអាងថា ៖ នាងខ្ញុំ និងប្តីឈ្មោះ [redacted] បានរៀបការតាមប្រពៃណីជាមួយគ្នាកាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ មានសំបុត្រអាពាហ៍ពិពាហ៍លេខ ៦៣ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ។ ក្រោយពេលរៀបការជាមួយគ្នារហូតដល់បច្ចុប្បន្ននេះ ពួកខ្ញុំមានកូនចំនួន ២ (ពីរ) នាក់ ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៣ និងឈ្មោះ [redacted] កើតថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៥ ។ និងមានទ្រព្យសម្បត្តិរួមផ្ទះថ្ម១ល្វែង ទំហំ ៤,៥ ម៉ែត្រ គុណនឹង ៩ ម៉ែត្រ ដែល សង់លើដីរបស់នាងខ្ញុំ ចំណាយអស់ប្រាក់ចំនួន ៣០០០ (បីពាន់) ដុល្លាអាមេរិក ។ និងមានបំណុលរួមជំពាក់បងស្រីនាងខ្ញុំចំនួនពីរជីមាសដែលបានខ្ចីយកមកធ្វើផ្ទះ ។ ចាប់តាំងពីនាងខ្ញុំរៀបការជាមួយប្តីរបស់នាងខ្ញុំមក ប្តីនាងខ្ញុំតែងតែដើរផឹកស៊ីស្រវឹងស្ទើររាល់យប់ ពេលត្រលប់មកផ្ទះវិញបានរករឿងឈ្លោះប្រកែកជាមួយនាងខ្ញុំ ហើយពេលខ្លះទៀតក៏បានប្រើអំពើហិង្សាមកលើនាងខ្ញុំទៀងផង ។ បន្ទាប់មកនៅខែមីនា ឆ្នាំ២០១៨ ប្តីរបស់នាងខ្ញុំបានចុះចោលខ្ញុំ និងកូនៗរហូតដល់សព្វថ្ងៃនេះ ទុកឲ្យនាងខ្ញុំរកស៊ីចិញ្ចឹមកូនៗតែម្នាក់ឯង ដោយគាត់មិនបានជួយផ្គត់ផ្គង់លុយសម្រាប់ចិញ្ចឹមកូនៗនោះឡើយ ។ ហេតុនេះហើយធ្វើឲ្យនាងខ្ញុំអស់មនោសញ្ចេតនាជាប្តីប្រពន្ធនិងគ្នាតទៅទៀត ទើបនាងខ្ញុំដាក់ពាក្យបណ្តឹងមកតុលាការដើម្បីសុំលែងលះតាមច្បាប់តែម្តង ។ នាងខ្ញុំសូមឲ្យតុលាការសម្រេចដូចការទាមទារក្នុងកម្មវត្ថុនៃពាក្យបណ្តឹងរបស់នាងខ្ញុំចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ។

ចុងចម្លើយឈ្មោះ [redacted] បានទទួលដីកាកោះហៅពីតុលាការគ្រប់ដំណាក់កាលនីតិវិធី តែអវត្តមានដោយគ្មានមូលហេតុ ។

**៤.ចំណុចវិវាទ ៖** ការសុំលែងលះពីចុងចម្លើយឈ្មោះ [redacted] ។

**៥.ចំណុចគ្មានវិវាទ ៖** ដើមចោទ និងចុងចម្លើយពិតជាបានរៀបការជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមច្បាប់ ។

## សំអាងហេតុ

១.ដើមចោទឈ្មោះ [illegible] បានដាក់ពាក្យបណ្ដឹងសុំលែងលះប្ដីឈ្មោះ [illegible] ដោយមូលហេតុថា ចាប់តាំងពីចាប់ដៃគ្នាជាប្ដីប្រពន្ធមក ប្ដីរបស់ខ្លួនតែងតែផឹកស្រាស្រវឹងស្ទើរាល់ថ្ងៃ ហើយនិងបានរករឿងឈ្លោះប្រកែកគ្នា ពេលខ្លះក៏បានប្រើអំពើហិង្សាមកលើខ្លួនទៀតផង ។ ហើយនៅក្នុងខែមីនា ឆ្នាំ២០១៨ ចុងចម្លើយបានចុះចោលខ្លួន និងកូនៗ រហូតមកដល់សព្វថ្ងៃនេះ ដោយមិនបានផ្ដល់លុយសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារនោះទេ ធ្វើឲ្យខ្លួនអស់មនោសញ្ចេតនាជាប្រពន្ធប្ដីនឹងគ្នាតទៅទៀត ។ ឃើញថា ការអះអាងរបស់ដើមចោទ គឺស្របទៅតាមច្បាប់ដែលតុលាការគប្បីពិចារណាសម្រេចទៅតាមការស្នើសុំ ដោយយោងតាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ។

២.ចុងចម្លើយឈ្មោះ [illegible] បានទទួលដីកាកោះហៅពីតុលាការគ្រប់ដំណាក់កាលនីតិវិធី តែអវត្តមានដោយគ្មានមូលហេតុ ។ ដូចនេះយោងតាមបញ្ញត្តិមាត្រា ២២១ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ថា ចុងចម្លើយបានទទួលស្គាល់ការទាមទាររបស់ដើមចោទ ។ គប្បីតុលាការសម្រេចតាមការទាមទារនេះ ។

៣.ដើមចោទទាមទារសិទ្ធិអំណាចមេបាលើកូនទាំងពីរនាក់ ដោយអះអាងថា តាំងពីរស់នៅបែកគ្នាជាមួយចុងចម្លើយ កូនៗបានរស់នៅជាមួយខ្លួន ហើយចុងចម្លើយក៏មិនដែលបានជួយផ្ដល់ប្រាក់សម្រាប់ចិញ្ចឹមកូនៗដែរ ។ ម្យ៉ាងទៀតចំពោះប្រាក់អាហារកិច្ចចិញ្ចឹមកូនៗទាំងពីរនាក់ គឺខ្លួនទាមទារឲ្យចុងចម្លើយផ្ដល់ប្រាក់ចំនួន ២០០.០០០ (ពីរ សែន) រៀល ក្នុងមួយខែ ។ ឃើញថា ការទាមទារនេះ គឺស្របទៅតាមច្បាប់ គប្បីតុលាការពិចារណាសម្រេចទៅតាមការទាមទារ ។

៤.ដើមចោទអះអាងថាខ្លួន និងប្ដីមានទ្រព្យសម្បត្តិរួមផ្ទះថ្មចំនួន ១ (មួយ) ល្វែង ទំហំ ៤,៥ ម៉ែត្រ គុណនឹង ៩ម៉ែត្រ សង់នៅលើដីដែលជាទ្រព្យសម្បត្តិដោយឡែករបស់ខ្លួន ស្ថិតនៅភូមិព្រែកតាព្រីង សង្កាត់ សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្ដាល ។ ហើយខ្លួនទាមទារផ្ទះនេះសម្រាប់ធ្វើជាជម្រកស្នាក់នៅជាមួយកូនៗ ។ ដូចនេះតុលាការគប្បីពិចារណាចំពោះការទាមទារនេះ ។

៥.ចំពោះប្រាក់ប្រដាប់ក្ដីតុលាការគប្បីឲ្យគូភាគីទទួលបន្ទុកម្នាក់ពាក់កណ្ដាល តាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**៦.ភស្តុតាងជាឯកសារមាន:**

-សំបុត្រអាពាហ៍ពិពាហ៍លេខ ៦៣ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១ ។

-សំបុត្រកំណើតឈ្មោះ [illegible] លេខ ២៧ សៀវភៅលេខ ១០/២០១៣ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ ២០១៣ ។

-សំបុត្រកំណើតឈ្មោះ [illegible] លេខ ០៥១ សៀវភៅលេខ ០១/២០១៩ ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៩ ។

-លិខិតធ្វើអំណោយផ្ដាច់ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៩ ។

# សេចក្តីសម្រេចបញ្ចប់

១.ឲ្យដើមចោទឈ្មោះ [illegible] ភេទស្រី អាយុ២៩ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅខេត្តកណ្តាល លែងលះពីចុងចម្លើយឈ្មោះ [illegible] ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិព្រែកក្រាញ់ ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល ។

២.ប្រគល់សិទ្ធិអំណាចមេបាលើកូនឈ្មោះ [illegible] ភេទស្រី កើតថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៣ និងឈ្មោះ [illegible] ភេទស្រី កើតថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៥ ឲ្យទៅដើមចោទឈ្មោះ [illegible] ជាម្តាយ ។

៣.បង្គាប់ឲ្យចុងចម្លើយឈ្មោះ [illegible] បង់ប្រាក់អាហារកិច្ចចិញ្ចឹមកូនៗចំនួន ២០០.០០០ (ពីរសែន) រៀល ក្នុងមួយខែ ឲ្យទៅដើមចោទឈ្មោះ [illegible] រហូតដល់កូនពេញវ័យនីតិភាព ។

៤.ទុកសិទ្ធិឲ្យចុងចម្លើយជាឪពុកដែលមិនបានទទួលសិទ្ធិអំណាចមេបាលើកូនៗ ទៅសាកសួរសុខទុក្ខប្រាស្រ័យទាក់ទងជាមួយកូនៗ ។

៥.ប្រគល់ផ្ទះថ្មចំនួន ១ (មួយ) ល្វែង ទំហំ ៤,៥ម៉ែត្រ គុណនឹង ៩ម៉ែត្រ ស្ថិតនៅភូមិព្រែកតាព្រីង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល ឲ្យទៅដើមចោទឈ្មោះ [illegible] សម្រាប់ស្នាក់នៅជាមួយកូនៗ ។

៦.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់គូភាគីម្នាក់ពាក់កណ្តាល ។

សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ចំពោះមុខដើមចោទ និងកំបាំងមុខចុងចម្លើយ ។ បើកសិទ្ធិទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ចៅក្រម**

[illegible]ជួន–វណ្ណះ

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យសុំដីកាសម្រេចបង្គាប់ឲ្យផ្តល់អាហារកាតព្វកិច្ច

**អ្នកដាក់ពាក្យសុំ** ៖ ឈ្មោះ X ភេទស្រី អាយុ ៥០ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ (គ្មាន) ផ្លូវលំ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៤ រាជធានីភ្នំពេញ។

**ភាគីម្ខាងទៀតនៃពាក្យសុំ** ៖ ឈ្មោះ Y ភេទប្រុស អាយុ ៤០ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ១០ ផ្លូវលេខ ៣១០ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៥ រាជធានីភ្នំពេញ។

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖ សំណើសុំតុលាការចេញដីកាសម្រេចដែលមានខ្លឹមសារថា ៖

(១) បង្គាប់ឲ្យឈ្មោះ Y បង់ប្រាក់ចំនួន **US$ ២០០ (ពីររយ) ដុល្លារអាមេរិក** ក្នុងមួយខែ គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤

(២) ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ Y

**យោង** ៖-មាត្រា **១១៤០** ដល់មាត្រា **១១៤៣** នៃក្រមរដ្ឋប្បវេណី

-មាត្រា **០៣** និងមាត្រា **២៦** នៃច្បាប់នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

សេចក្តីដូចមានកំណត់ និងយោងខាងលើ នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន**មេត្តាជ្រាបថា៖

..........................................................................................................

..........................................................................................................

..........................................................................................................

**ក-អង្គហេតុដែលជាមូលហេតុនៃការទាមទារ**

-

-

-

**ខ-វត្ថុតាងជាឯកសារ**

-

-

-

សេចក្ដីដូចជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាសម្រេចតាមការស្នើសុំដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**ស្នាមម្រាមដៃ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>ដីកាសម្រេចបង្គាប់ឲ្យផ្តល់អាហារកាតព្វកិច្ច</u>

**សាលាដំបូងរាជធានីភ្នំពេញ**

-សំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងលេខ ០១ ចុះថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤

-ដីកាសម្រេចលេខ ០១ "ក" ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤

យើង W ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

-បានឃើញមាត្រា ០៣ និងមាត្រា ២៦ នៃច្បាប់នីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង

-បានឃើញមាត្រា ១១៤០ ដល់មាត្រា ១១៤៣ នៃក្រមរដ្ឋប្បវេណី

-បានឃើញសំណុំរឿងរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹងលេខ ០១ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ

រវាងអ្នកដាក់ពាក្យសុំឈ្មោះ X អាយុ ៥០ ឆ្នាំ ភេទស្រី សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ (គ្មាន) ផ្លូវលំ ក្រុម១ ភូមិ២ សង្កាត់៣ ខណ្ឌ៤ រាជធានីភ្នំពេញ។

និងភាគីម្ខាងទៀតនៃពាក្យសុំឈ្មោះ Y អាយុ ៤០ ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ១០ ផ្លូវលេខ ៣១០ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៥ រាជធានីភ្នំពេញ។

**ខ្លឹមសារនៃដីកាសម្រេចដែលត្រូវបានស្នើសុំដោយអ្នកដាក់ពាក្យសុំ** (X)៖

-បង្គាប់ឲ្យឈ្មោះ Y បង់ប្រាក់ចំនួន **US$ ២០០ (ពីររយ) ដុល្លារអាមេរិក** ក្នុងមួយខែ គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤

-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ Y

### ក-ដំណើររឿង

ក-១ ការអះអាងរបស់ X ៖

ក-២ ការអះអាងរបស់ Y ៖

### ខ-ភស្តុតាងក្នុងសំណុំរឿង

ខ-១ ភស្តុតាងរបស់ X ៖

ខ-២ ភស្តុតាងរបស់ Y ៖

### នាពេលសាកសួរភាគីនៃសំណុំរឿង

-

-

### សំអាងហេតុ

-

**ហេតុដូច្នេះវិនិច្ឆ័យសេចក្តី**

១-បង្គាប់ឲ្យឈ្មោះ Y បង់ប្រាក់ចំនួន **US$ ២០០ (ពីររយ) ដុល្លារអាមេរិក** ក្នុងមួយខែ គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៤ ទៅឲ្យឈ្មោះ X

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ Y

ដីកាសម្រេចនេះទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ នៅចំពោះមុខអ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតនៃពាក្យសុំ។

ទុកសិទ្ធិឲ្យប្តឹងជំទាស់ក្នុងអំឡុងពេល ០២ ( ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃទទួលបានការជូនដំណឹងអំពីដីកាសម្រេចនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤

**ចៅក្រម**